# មេរៀនទី ៣ ព្រះគ្រិស្ត៖ ការបើកសំដែងឲ្យមើលឃើញ នៃព្រះជាម្ចាស់ដែលគេមិនអាចមើលឃើញ

"គាត់ពិតជាដូចឪពុកគាត់ណាស់" ។ តើអ្នកធ្លាប់ឮនរណាម្នាក់និយាយអំពីក្មេងប្រុសម្នាក់យ៉ាងដូច្នេះដែរឬទេ? ពេលខ្លះយើងសួរខ្លួនឯងថា៖ "តើគាត់ទាំងពីរនាក់ដូចគ្នាយ៉ាងណា?" ប្រសិនបើឪពុកហើយនឹងកូនពីរនាក់ *មើលទៅ* ដូចគ្នា យើងអាចឃើញយ៉ាងងាយ ប៉ុន្តែពេលខ្លះភាពស្រដៀងគ្នានេះមិនសូវជាច្បាស់ប៉ុន្មានទេ។ ឧទាហរណ៍ ពួកគេប្រហែលជាមានទង្វើដូចគ្នា ឬ របៀបគិតដូចគ្នា ឬ មានបុគ្គលិកលក្ខណៈដូចគ្នាខ្លាំង។ តាមរយៈការមើលទៅកាន់ក្មេងម្នាក់ អ្នកអាចមើលឃើញជាច្រើនចំណុចអំពីឪពុករបស់គេ។

ព្រះយេស៊ូបានយាងមកក្នុងលោកីយ៍នេះដើម្បីបង្ហាញយើងថា ព្រះជាម្ចាស់ព្រះវរបិតាទ្រង់មានសណ្ឋានយ៉ាងដូចម្ដេច? ទ្រង់គឺជាអ្នកតំណាងដែលគេអាចមើលឃើញ សម្រាប់ព្រះវរបិតាដែលគេមិនអាចមើលឃើញ។ ព្រះយេស៊ូស្នងលក្ខណសម្បត្តិធម្មជាតិ និងខាងឯសីលធម៌របស់ព្រះជាម្ចាស់។ តាមរយៈការអស្ចារ្យនៃការមានព្រះជន្មរស់ឡើងវិញ ទ្រង់បានយកនិស្ស័យ និង សណ្ឋានជាមនុស្សមកលើអង្គទ្រង់។ ធ្វើដូច្នេះ ទ្រង់បានបើកសំដែងឲ្យឃើញពីគុណសម្បត្តិរបស់ព្រះជាម្ចាស់ និង ផ្សាភ្ជាប់គុណសម្បត្តិទាំងនេះទៅកាន់មនុស្សផងដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "អ្នកណាបានឃើញខ្ញុំ ក៏បានឃើញព្រះបិតាដែរ។" (គម្ពីរយ៉ូហាន ១៤:៩)

នៅក្នុងមេរៀននេះ យើងនឹងពិចារណាទៅលើគោលលិទ្ធិដែលទាក់ទងនឹងព្រះយេស៊ូគ្រិស្ត ដែលជា "រស្មីនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ។" (គម្ពីរហេប្រឺ១:៣)។ នៅពេលដែលយើងគិតអំពីពេលវេលាដែលទ្រង់គង់នៅលើផែនដី និង អំពីរបៀបដែលទ្រង់ឆ្លុះបញ្ចាំងពីព្រះវរបិតាសូមឲ្យយើងធ្វើដោយស្មោះអស់ពីចិត្ត ដើម្បីឲ្យយើងអាចឆ្លុះបញ្ចាំងពីភាពស្រស់ស្អាតនៃព្រះបុត្រាទៅកាន់អ្នកដទៃ តាមរបៀបដូចគ្នានោះដែរ។

## គម្រោងមេរៀន

ក. ភាពជាមនុស្សរបស់ព្រះគ្រិស្ដ
ខ. ភាពជាព្រះរបស់ព្រះគ្រិស្ដ
គ. ការរួមមកតែមួយនៃភាពជាព្រះ និង ភាពជាមនុស្សនៅក្នុងព្រះគ្រិស្ដ
ឃ. រាជកិច្ចរបស់ព្រះគ្រិស្ដ

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ផ្ដល់ភស្ដុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពពេញវ័យរបស់ព្រះយេស៊ូ។
២. ផ្ដល់ភស្ដុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពជាព្រះរបស់ព្រះយេស៊ូ។
៣. រៀបរាប់គុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិ ដែលបង្ហាញថាព្រះយេស៊ូជាព្រះជាម្ចាស់។
៤. ពិភាក្សាអំពីសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងការចាប់បដិសន្ធិ។
៥. បកស្រាយពីមូលហេតុដែលកិច្ចការរបស់ព្រះគ្រិស្ដ មានសារៈសំខាន់សម្រាប់មនុស្សជាតិ។

## សកម្មភាពក្នុងការសិក្សា

១. សិក្សាតាមដំណើរវិវឌ្ឍន៍របស់មេរៀន ដោយយោងទៅតាមដំណើរការនៃគម្រោងមេរៀន នៅក្នុងមេរៀនទី១ និង ទី២។
២. ត្រូវធ្វើឲ្យប្រាកដថា អ្នកបានឆ្លើយសំណួរនៅក្នុងមេរៀនដោយខ្លួនឯង មុនពេលអ្នកបើកមើលចម្លើយដែលបានផ្ដល់ជូននៅចុងបញ្ចប់នៃមេរៀន។ រំឭកឡើងវិញនូវលំហាត់ទាំងឡាយណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។ បន្ទាប់មកធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

## ពាក្យសំខាន់ៗ

| | | |
|---|---|---|
| បុព្វបុរស | អ្នកសម្រុះសម្រួល | ផ្សះផ្សា |
| ការលើកឡើងទៅស្ថានសួគ៌ | ខ្សែស្រឡាយ | ការប្រោសលោះ |
| ភាពជាព្រះ | អ្នកសម្របសម្រួល | អ្នកតំណាង |
| ចម្លែក | ជីវិតដែលអាចស្លាប់ | រងឥទ្ធិពល |
| មនុស្សជាតិ | ពិន័យ | អធិធម្មជាតិ |
| ការចាប់បដិសន្ធិ | | |

# ក. ភាពជាមនុស្សរបស់ព្រះយេស៊ូ

**វត្ថុបំណងទី១.** *ផ្តល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពពេញវ័យរបស់ព្រះយេស៊ូ។*

នៅក្នុងចំណោមធាតុផ្សំផ្សេងៗនៃជំនឿរបស់គ្រិស្តបរិស័ទ *ការចាប់បដិសន្ធិ*របស់ព្រះយេស៊ូគ្រិស្តជាអម្ចាស់នៃយើង គឺពិតជាមូលដ្ឋានគ្រឹះដំបូងបំផុតដែលមិនអាចប្រកែកបាន។ *ការចាប់បដិសន្ធិ* សំដៅទៅលើការរួមតែមួយនៃភាពជាព្រះ ជាមួយនឹងភាពជាមនុស្សនៅក្នុងអង្គព្រះយេស៊ូគ្រិស្ត។ បទគម្ពីរបានបង្រៀនយ៉ាងច្បាស់ថា ទ្រង់ដែលជាបុត្រដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ បានក្លាយជាមនុស្សដើម្បីបំណងព្រះហឫទ័យក្នុងការសង្គ្រោះយើងរាល់គ្នា។ ព្រះជាម្ចាស់បានធ្វើការតាមរបៀបមួយថ្មី នៅក្នុងលោកីយ៍នេះ នៅពេលបុត្ររបស់ទ្រង់ចាប់កំណើតជា "សាច់ឈាម" ។ ព្រះយេស៊ូបានចាប់ទំផ្ទៃនាងក្រមុំព្រហ្មចារីម៉ារី ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងកិច្ចការនៃការបង្កើតដ៏ពិសេសនេះ ព្រះជាម្ចាស់បានបំបែកច្រវ៉ាក់ខ្សែស្រឡាយមនុស្ស ហើយបាននាំមកនូវភាវៈដ៏អស្ចារ្យមួយ។

អាថ៌កំបាំងនៅជុំវិញហេតុការណ៍ដ៏អស្ចារ្យនេះ នឹងត្រូវសាបរលាបទៅ នៅពេលណាយើងដឹងថា នេះគឺជាផ្នែកមួយនៃសកម្មភាពថ្មីរបស់ព្រះជាម្ចាស់។ ព្រះបុត្រារបស់ព្រះជាម្ចាស់យាងមកដើម្បីសង្គ្រោះមនុស្ស ដែលជាភាវៈមានសាច់ឈាម ដោយការយាងមកចាប់កំណើតមកមានសាច់ឈាមដោយព្រះអង្គផ្ទាល់។ ទ្រង់បានធ្វើកិច្ចការ ដើម្បីប្រទានការសង្គ្រោះដល់មនុស្សជាតិ ដោយការសុគតរបស់ទ្រង់។ ជាមួយនឹងការចាប់បដិសន្ធិនេះ ព្រះជាម្ចាស់ដាក់ឲ្យផែនការនៃការប្រោសលោះនៅលើផែនដី ចាប់ដំណើរការទៅមុខ៖ "ប៉ុន្តែ លុះដល់ពេលកំណត់ហើយ ព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គអោយមកប្រសូតចេញពីស្ត្រី ហើយប្រសូតក្រោមអំណាចរបស់វិន័យផង" (គម្ពីរកាឡាទី៤:៤) ។ គ្មានមធ្យោបាយណាផ្សេងទៀត ដែលអាចឲ្យទ្រង់សម្រេចបំណងព្រះហឫទ័យក្នុងការសង្គ្រោះ បានឡើយ។

ដូច្នេះ ការចាប់បដិសន្ធិ គឺជាចំណុចផ្លាស់ប្តូរសម្រាប់មនុស្សជាតិដែលពោរពេញដោយអំពើបាប ដ្បិតការនេះធ្វើឲ្យមានការផ្សះផ្សា (នាំមកជួបគ្នាម្តងទៀត) រវាងព្រះជាម្ចាស់ និង មនុស្សជាតិ កើតឡើងបាន។ ដោយសារភាពជាមនុស្សរបស់ព្រះយេស៊ូ មានសារៈសំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់ដល់ម្ល៉េះ ដែលយើងចាំបាច់ត្រូវពិចារណាអំពីភស្តុតាងខ្លះៗអំពីភាពជាមនុស្សរបស់ទ្រង់។ ភស្តុតាងទាំងនោះ រួមមានបុព្វបុរសជាមនុស្សរបស់ទ្រង់ ការរីកធំធាត់ជាមនុស្ស ទិដ្ឋភាពជាមនុស្ស ដែនកំណត់ជាមនុស្ស និង ឈ្មោះជាមនុស្សរបស់ទ្រង់។

## បុព្វបុរស និង ការរីកធំធាត់ជាមនុស្ស

អ្នកនិពន្ធដំណឹងល្អពីរនាក់ មានលោកម៉ាថាយ និង លោកលូកា បានតាមដានបុព្វបុរសរបស់ព្រះគ្រិស្ត។ តាមពិតទៅ លោកម៉ាថាយ បានតាមដានខ្សែស្រឡាយរបស់ទ្រង់ រហូតទៅដល់ស្តេចដាវីឌ និងលើសពីនោះទៅទៀត រហូតដល់លោកអប្រាហាំជាអយ្យកោរបស់ទ្រង់ (គម្ពីរម៉ាថាយ ១:១-១៧)។ វត្ថុបំណងពីរយ៉ាងរបស់លោកគឺ៖

១. ដើម្បីបញ្ជាក់ថាព្រះយេស៊ូ គឺមកពីខ្សែស្រឡាយព្រះបាទដាវីឌ និង ជាអ្នកស្នងរាជបល្ល័ង្កនៃសាសន៍អ៊ីស្រាអែល។ បើមិនដូច្នោះទេ គ្មានសាសន៍យូដាណាម្នាក់អាចទទួលស្គាល់ទ្រង់ជាស្តេច ឬ ជាព្រះមេស្ស៊ីរបស់ពួកគេបានឡើយ។

២. ដើម្បីបញ្ជាក់ថាព្រះយេស៊ូ ជាគ្រាប់ពូជរបស់លោកអប្រាហាំ ជាបុត្រដែលតាមរយៈបុត្រនេះ គ្រួសារទាំងអស់នៅលើផែនដីបានទទួលព្រះពរ (សូមមើលគម្ពីរលោកុប្បត្តិ ២២:១៧-១៨)។

លោកលូកាតាមដានខ្សែស្រឡាយរបស់ព្រះយេស៊ូ បកក្រោយរហូតដល់លោកអាដាំ ដែលជាមនុស្សដំបូងគេបង្អស់ (គម្ពីរលូកា៣:២៣-៣៨)។ ទោះជាយ៉ាងណា គោលបំណងរបស់លោកម៉ាថាយ និង លោកលូកា គឺដើម្បីសង្កត់ន័យទៅលើកការពិតនៃជីវិតជាមនុស្សរបស់ព្រះយេស៊ូ៖ ទ្រង់បាន "មកប្រសូតចេញពីស្ត្រី" (គម្ពីរកាឡាទី៤:៤)។

នៅពេលដែលយើងនិយាយថា ព្រះយេស៊ូមានបុព្វបុរសជាមនុស្ស យើងត្រូវបញ្ជាក់បង្ហាញឲ្យបានច្បាស់ៗ ថា ទ្រង់មិនមានឪពុកដែលមាននិស្ស័យជាមនុស្សនោះទេ។ ការប្រសូតរបស់ទ្រង់ គឺខុសពីការកើតរបស់មនុស្សទាំងអស់។ លោកលូកាបានកត់ត្រាឈុតឆាក ដែលទេវតាប្រាប់នាងម៉ារីថា នាងនឹងមានគភ៌ឆាប់ៗ ។ ការឆ្លើយតបភ្លាមៗរបស់នាងគឺ៖ "តើធ្វើដូចម្តេចនឹងអោយការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?" (គម្ពីរលូកា ១:៣៤) ។ ជាការឆ្លើយតបទៅនឹងសំណួររបស់នាងទាក់ទងនឹងការចាប់កំណើតដ៏អស្ចារ្យរបស់ព្រះយេស៊ូ ដែលហាក់ដូចជាមិនអាចកើតឡើងបាននោះ ទេវតាបានរំឭកនាងម៉ារីថា "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះឡើយ" (ខ៣៧)។ ការប្រសូតរបស់ព្រះយេស៊ូ គឺជាអព្ភូតហេតុដ៏អស្ចារ្យ ប៉ុន្តែកំណើតនោះជាកំណើតរបស់*មនុស្ស*។

ការរីកធំធាត់ខាងឯរូបកាយ និង គំនិតរបស់ព្រះយេស៊ូគឺផ្អែកទៅលើច្បាប់នៃការលូតលាស់របស់មនុស្សធម្មតា។ តាមពិតទៅ ការលូតលាស់ និង ការរីកធំធាត់របស់ទ្រង់ ជាសមាជិកសាមញ្ញម្នាក់នៃស្រុកណាសារ៉ែត ត្រូវបានទទួលស្គាល់ដោយមនុស្សដែលរស់នៅរួមក្រុងជាមួយទ្រង់ផងដែរ (គម្ពីរម៉ាថាយ ១៣:៥៥)។ លោកលូកាបាននិយាយថាព្រះយេស៊ូ "មានវ័យចំរើនឡើងជាលំដាប់ មានកម្លាំងកាន់តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញាញាណ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងព្រះកុមារនេះណាស់" (គម្ពីរលូកា២:៤០) ។ យើងដឹងថា ការរីកចម្រើនខាងឯព្រះតម្រិះរបស់ទ្រង់ គឺមិនមែនជាលទ្ធផលដែលបានមកពីការបង្ហាត់បង្រៀនដែលទ្រង់ទទួលនៅក្នុងសាលាក្នុងជំនាន់នោះទេ (គម្ពីរយ៉ូហាន៧:១៥) ។ ផ្ទុយទៅវិញ ការរីកចម្រើននោះបានមកពីការបណ្តុះបណ្តាលដែលទ្រង់ទទួលបានពី ឪពុកម្តាយដែលគោរពកោតខ្លាចព្រះជាម្ចាស់ ការទៅសាលាប្រជុំជាប្រចាំ (គម្ពីរលូកា ៤:១៦) ការចូលទៅក្នុងព្រះវិហារប្រកបដោយជំនឿ (គម្ពីរលូកា ២:៤១) ការសិក្សា និង ការអនុវត្តតាមបទគម្ពីរដោយជំនឿ និង ការអធិស្ឋាន (គម្ពីរម៉ាកុស ១:៣៥ គម្ពីរយ៉ូហាន៤:៣២-៣៤)។

## *លំហាត់អនុវត្តន៍*

១ ចូរអានគម្ពីរលូកា២:៥២ ។ ខនេះបង្ហាញថា ព្រះជន្មរបស់ព្រះយេស៊ូបានរីកចម្រើនខាងឯ

ក) សតិបញ្ញា

ខ) វិញ្ញាណ

គ) រូបកាយ

ឃ) សង្គម

## សណ្ឋាន និង ដែនកំណត់ជាមនុស្ស

ភស្តុតាងគ្រប់ទាំងអស់បានបង្ហាញថា លក្ខណៈរូបកាយរបស់ព្រះយេស៊ូក៏ស្រដៀងទៅនឹងមនុស្សដទៃទៀតដែរ។ តាមពិតទៅ ទ្រង់មានលក្ខណៈដូចមនុស្សដទៃទៀត ទាំងនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ ដែលនៅពេលទ្រង់ប្រកាសថាទ្រង់គឺតែមួយជាមួយនឹងព្រះជាម្ចាស់ ធ្វើឲ្យអ្នកស្តាប់ទ្រង់ ខឹងសម្បារនឹងទ្រង់យ៉ាងខ្លាំង ។ ពួកគេបានឆ្លើយតបទាំងកំហឹងថា ទ្រង់គឺ "ជាមនុស្ស" ហើយគ្មានសិទ្ធិអ្វីនឹងមកប្រកាសថាខ្លួនជាព្រះជាម្ចាស់យ៉ាងដូច្នេះឡើយ (គម្ពីរយ៉ូហាន ១០:៣៣)។

នៅពេលដែលទេសាភិបាលរ៉ូម៉ាំង លោកពីឡាត នាំព្រះយេស៊ូមកឈរនៅចំពោះមុខពួកយូដាមុនធ្វើការប្រកាសទោសរបស់ទ្រង់។លោកពីឡាតមានប្រសាសន៍ថា៖ "មើល៍ មនុស្សហ្នឹងហើយ" (គម្ពីរយ៉ូហាន ១៩:៥) ។ នៅពេលដែលព្រះយេស៊ូទទួលការកាត់ទោសនៅចំពោះមុខអ្នកកាត់ក្តីរ៉ូម៉ាំង គ្មាននរណាម្នាក់សួរពីភាពជាមនុស្សរបស់ព្រះអង្គឡើយ។ ក្រោយមកលោកសាវ័កប៉ូលបានបញ្ជាក់ទៅកាន់ពិភពលោកនៅក្នុងសតវត្សរ៍ទីមួយនោះថា "ឃើញទ្រង់មានភាពជាមនុស្ស" (គម្ពីរភីលីព ២:៨ គម្ពីរបកប្រែចាស់)។

គ្មានមិត្តសម្លាញ់របស់ព្រះយេស៊ូ ម្នាក់ណាដែលសង្ស័យថា ទ្រង់គឺជាមនុស្សនោះឡើយ។ ជារឿយៗ ពួកគេស្ញប់ស្ញែងជាមួយនឹងរឿងដែលថា ទ្រង់គឺជាបុរសដ៏អស្ចារ្យម្នាក់៖ "តើលោកនេះជានរណាបានជាខ្យល់ព្យុះ និងសមុទ្រស្តាប់បង្គាប់លោកដូច្នេះ?" (គម្ពីរម៉ាកុស ៤:៤១)។

នៅពេលដែលព្រះយេស៊ូមកចាប់កំណើតជាមនុស្ស ទ្រង់ស្ម័គ្រព្រះទ័យ ដាក់អង្គទ្រង់នៅក្នុងដែនកំណត់របស់មនុស្ស។ ជាលទ្ធផល ពេលខ្លះទ្រង់ក៏មានការនឿយព្រះកាយ (គម្ពីរយ៉ូហាន៤:៦) ឃ្លាន (គម្ពីរម៉ាកុស ១១:១២) និង ស្រេក (គម្ពីរយ៉ូហាន ១៩:២៨) ។ ទ្រង់បានឆ្លងកាត់សេចក្តីល្បួង (គម្ពីរម៉ាថាយ ៤:១-១១) និង ទទួលបានកម្លាំងពីព្រះវរបិតា ក្នុងពេលទ្រង់អធិស្ឋាន (គម្ពីរលូកា ២២:៤២-៤៤) ។ ទ្រង់ក៏បានឆ្លងកាត់ការឈឺចាប់ (គម្ពីរ១ពេត្រុស ៤:១) និង ចុងក្រោយទ្រង់ក៏បានឆ្លងកាត់សេចក្តីស្លាប់ (គម្ពីរ ១កូរិនថូស ១៥:៣)។ នេះគឺជាភស្តុតាងដ៏អស្ចារ្យបំផុតអំពីដែនកំណត់នៃមនុស្សរបស់ទ្រង់បានធ្វើទៅចំពោះទ្រង់។

# ព្រះនាមជាមនុស្ស

ព្រះនាមដែលព្រះយេស៊ូទទួលបានក៏បញ្ជាក់ពីភាពជាមនុស្សរបស់ព្រះអង្គផងដែរ។ នៅពេលដែលទេវតាបានប្រាប់លោកយ៉ូសែបអំពីបុត្រដែលនឹងត្រូវប្រសូតមក ទេវតានោះបានបង្គាប់ឲ្យលោកយ៉ូសែបដាក់ឈ្មោះបុត្រនោះថា *យេស៊ូ* ដែលស្រដៀងទៅនឹងឈ្មោះនៅក្នុងភាសាក្រិកនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ គឺ *យ៉ូស្វេ* (គម្ពីរម៉ាថាយ១:២១) ដែលមានន័យថា "អ្នកសង្គ្រោះ" ។ ទ្រង់ក៏ត្រូវបានគេហៅថា "ព្រះរាជវង្សរបស់ព្រះបាទដាវីឌ" និង "ពូជពង្សរបស់លោកអប្រាហាំ" (គម្ពីរម៉ាថាយ ១:១)។ ប៉ុន្តែព្រះនាមដែលទ្រង់គាប់ព្រះទ័យឲ្យគេហៅទ្រង់នៅក្នុងបទគម្ពីរ គឺ *បុត្រមនុស្ស* ជានាមដែលសំដែងយ៉ាងច្បាស់អំពីភាពជាមនុស្សរបស់ទ្រង់។ ព្រះយេស៊ូបានប្រើនាមនេះ នៅពេលទ្រង់មានព្រះបន្ទូលអំពីអង្គទ្រង់ (គម្ពីរម៉ាថាយ ២៦:៦៤-៦៥)។ អ្នកនឹងសំគាល់ឃើញថា ទោះបីជា ទ្រង់មិនបានប្រកាសថាទ្រង់គឺជាបុត្រមនុស្ស*ម្នាក់*នោះទេ តែទ្រង់បានប្រកាសថាទ្រង់គឺជាបុត្ររបស់មនុស្ស ។ ពាក្យនេះ មិនគ្រាន់តែបញ្ជាក់ថាទ្រង់គឺជាមនុស្សម្នាក់នោះទេ ប៉ុន្តែក៏បញ្ជាក់ថាទ្រង់គឺជាអ្នកតំណាងឲ្យមនុស្សជាតិទាំងអស់។

## *លំហាត់អនុវត្តន៍*

---

២ ចូរអានគម្ពីរលូកា ២:៤០, ៥១; ៨:១៩-២១ និងគម្ពីរយ៉ូហាន ៧:១-៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ ចូរគូសរង្វង់ជុំវិញអក្សរខាងមុខចម្លើយត្រឹមត្រូវ។

ក) ព្រះយេស៊ូបានឆ្លងកាត់កុមារភាព និង ដំណាក់កាលនៃការអភិវឌ្ឍន៍ធម្មតា ទ្រង់បង្ហាញឲ្យឃើញពីការរីកចម្រើនខាងឯរូបកាយ គំនិត និង ខាងឯវិញ្ញាណ។

ខ) ទោះបីជាទ្រង់បង្ហាញឲ្យឃើញពីសមត្ថភាពមិនធម្មតាតាំងពីវ័យក្មេង ព្រះយេស៊ូនៅតែស្ថិតនៅក្រោមការដឹកនាំរបស់ឪពុកម្ដាយរបស់ទ្រង់។

គ) នៅពេលដែលព្រះយេស៊ូ ទទួលបានចំណាប់អារម្មណ៍នៅពេលទ្រង់បង្រៀន ឪពុកម្ដាយរបស់ទ្រង់បានយល់ច្បាស់ពីបេសកកម្មរបស់ទ្រង់ ហើយមិនបានទាមទារអ្វីពីទ្រង់វិញឡើយ។

ឃ) បងប្អូនរបស់ព្រះយេស៊ូ បានទទួលស្គាល់ថាទ្រង់គឺលើសពីមនុស្សធម្មតា តាមរយៈកិច្ចការដ៏អស្ចារ្យរបស់ទ្រង់ ហើយពួកគេបានគាំទ្រព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់។

៣ ចូរផ្គូផ្គងភស្តុតាងនៃភាពជាមនុស្សរបស់ព្រះយេស៊ូ (ខាងស្ដាំ) ទៅនឹងការរៀបរាប់អំពីភស្តុតាងនោះ (ខាងឆ្វេង)។

| | |
|---|---|
| .........ក) ព្រះយេស៊ូបានឆ្លងកាត់ការនឿយហត់ ការឃ្លាន ការស្រេក ការឈឺចាប់ និង ទីបំផុតការសុគត។ | ១) បុព្វបុរសជាមនុស្ស |
| .........ខ) ព្រះយេស៊ូត្រូវបានគេហៅថា ដោយប្រើទម្រង់ភាសាក្រិកនៃពាក្យថា *យ៉ូស្វេ* នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ បូករួមទាំងនាមដទៃទៀតដែរ។ | ២) ការអភិវឌ្ឍន៍ជាមនុស្ស |
| .........គ) អ្នកនិពន្ធព្រះគម្ពីរ បានរៀបរាប់ពីខ្សែស្រឡាយរបស់ព្រះយេស៊ូ រហូតដល់ព្រះបាទដាវីឌ លោក | ៣) សណ្ឋានជាមនុស្ស |
| | ៤) ដែនកំណត់ជាមនុស្ស |
| | ៥) ព្រះនាមជាមនុស្ស |

អប្រាហាំ និង លោកអដាំ។

........ឃ) ពួកទេសាភិបាលរ៉ូម៉ាំង ដែលបានកាត់ទោសព្រះយេស៊ូ បានសំគាល់ទ្រង់ដោយនិយាយថា "មើល៍ មនុស្សហ្នឹងហើយ" (គម្ពីរយ៉ូហាន ១៩:៥)។

........ង) ព្រះយេស៊ូបង្ហាញពីការរីកចម្រើនខាង ឯគំនិត រូបកាយ វិញ្ញាណ និង សង្គម។

# ខ. ភាពជាព្រះរបស់ព្រះគ្រិស្ត

**វត្ថុបំណងទី២.** *ផ្ដល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពជាព្រះរបស់ព្រះយេស៊ូ។*

យើងបានពិនិត្យទៅលើភស្តុតាងក្នុងព្រះគម្ពីរ សម្រាប់ភាពជាមនុស្សរបស់ព្រះគ្រិស្ត ហើយយើងឃើញថា ភស្តុតាងនេះគឺពិតជាមានភាពប្រាកដប្រជាមែន។ ឥឡូវនេះ យើងនឹងពិចារណាទៅលើការពិតក្នុងព្រះគម្ពីរដែលទាក់ទងនឹងភាពជាព្រះរបស់ព្រះគ្រិស្ត និង សារៈសំខាន់នៃផ្នែកមួយនេះរបស់ទ្រង់វិញម្ដង។

## សិទ្ធិជាព្រះជាម្ចាស់

ភស្តុតាងដំបូងដែលយើងនឹងពិចារណា សម្រាប់ភាពជាព្រះរបស់ព្រះគ្រិស្តគឺថា *ទ្រង់ប្រើប្រាស់សិទ្ធិដែលមានតែព្រះជាម្ចាស់មានសិទ្ធិនោះ។* សិទ្ធិជាព្រះជាម្ចាស់ រួមមាន *ការទទួលបាននូវការថ្វាយបង្គំពីមនុស្ស ការអត់ទោសបាប ការប្រោសមនុស្សស្លាប់ឲ្យរស់* និង *សិទ្ធិក្នុងការវិនិច្ឆ័យទោស។*

ដោយសារតែព្រះជាម្ចាស់បានហាមឃាត់នៅក្នុង ក្រឹត្យវិន័យទាំងដប់ប្រការ នូវការថ្វាយបង្គំព្រះដទៃ (គម្ពីរនិក្ខមនំ ២០:៣-៥) នោះការថ្វាយបង្គំនេះ គឺជាទង្វើប្រមាថ ប្រសិនបើព្រះយេស៊ូមិនមែនជាព្រះដទៃទេនោះ។ (*ការប្រមាថ* គឺជាការ មើលងាយ ឬ ការថ្លែងប្រកាសយ៉ាងខុសឆ្គងថាខ្លួនជាព្រះជាម្ចាស់)។ នៅពេលដែលព្រះយេស៊ូត្រូវបានល្បួងលដោយអារក្ស ទ្រង់បានបញ្ជាក់ម្ដងហើយម្ដងទៀត អំពីក្រិត្យវិន័យ ដែលតម្រូវឲ្យថ្វាយបង្គំព្រះអម្ចាស់ និង បម្រើទ្រង់តែមួយ( គម្ពីរម៉ាថាយ ៤:១០)។ ប៉ុន្តែទ្រង់បានប្រកាស ពីសិទ្ធិទទួលបានការថ្វាយបង្គំរបស់ទ្រង់។

ព្រះគម្ពីរបានបង្ហាញថា នៅពេលដែលមនុស្សមានភាពល្ងង់ខ្លៅ បានព្យាយាមថ្វាយបង្គំពួកសាវ័កមនុស្សរបស់ព្រះជាម្ចាស់ទាំងនេះ បដិសេធយ៉ាងខ្លាំង ដោយមិនព្រមទទួលការថ្វាយបង្គំរបស់ពួកគេឡើយ (គម្ពីរកិច្ចការ ១០:២៥- ២៦; ១៤:១១-១៨)។ សូម្បីតែពួកទេវតាដ៏វិសុទ្ធដ៏បដិសេធមិនទទួលការថ្វាយបង្គំដែលបានផ្ដល់ទៅឲ្យពួកគេ យ៉ាងខុសឆ្គងនោះដែរ (គម្ពីរវិវរណៈ ១៩:១០; ២២:៨-៩)។ នៅពេលដែលពួកគេសាវ័កដែលជាមនុស្សសាមញ្ញ និង ពួកទេវតាដ៏មានឫទ្ធិ បដិសេធមិនទទួលការថ្វាយបង្គំ ព្រះយេស៊ូបានទទួលយកការថ្វាយបង្គំវិញ ដ្បិតនោះជាសិទ្ធិរបស់ព្រះអង្គ។ ទ្រង់បានប្រកាសថា ការតម្កើងទ្រង់គឺជាកាតព្វកិច្ចរបស់មនុស្សទាំងអស់ (គម្ពីរយ៉ូហាន៥:២៣)។

ម្យ៉ាងវិញទៀត យើងឃើញថា ព្រះយេស៊ូបានប្រើប្រាស់សិទ្ធិរបស់ទ្រង់ ដើម្បីអត់ទោសបាប ដែលជាសិទ្ធិ ទុកសម្រាប់តែព្រះជាម្ចាស់តែមួយគត់ (គម្ពីរម៉ាកុស ២:៥-៧) ។ ព្រះយេស៊ូមិនបានស្ទាក់ស្ទើរក្នុងការប្រើប្រាស់សិទ្ធិមួយនេះឡើយ ទោះបីជាសត្រូវរបស់ទ្រង់ ថ្នាំងថ្នាក់ជាមួយនឹងរឿងនេះយ៉ាងខ្លាំង (គម្ពីរម៉ាថាយ ៩:២-៦)។

ព្រះយេស៊ូក៏បានប្រើប្រាស់សិទ្ធិនេះដើម្បីប្រទានជីវិត (គម្ពីរយ៉ូហាន ៥:២១;១០:១០)។ យ៉ាងហោចមានបីលើក ដែលព្រះយេស៊ូបានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ (គម្ពីរលូកា ៧:១១-១៧; ៨:៤០-៥៦ គម្ពីរយ៉ូហាន ១១:១-៤៤)។ នៅពេលអនាគត អស់អ្នកដែលបានស្លាប់ទៅ នឹងរស់រានមានជីវិតឡើងវិញ ដោយព្រះបន្ទូលដ៏មានឫទ្ធានុភាពរបស់ព្រះអង្គ (គម្ពីរយ៉ូហាន ៥:២១-៣០) ។ ជាក់ស្តែង សិទ្ធិក្នុងការផ្តល់ជីវិត គឺជាសិទ្ធិដែលគ្មានមនុស្សធម្មតាម្នាក់ណា អាចធ្វើបានដោយអំណាចផ្ទាល់ខ្លួនបានឡើយ។

ឧទាហរណ៍ទីបួន អំពីសិទ្ធិជាព្រះជាម្ចាស់របស់ព្រះយេស៊ូ គឺសិទ្ធិរបស់ទ្រង់ក្នុងការវិនិច្ឆ័យទោស៖ " ព្រះបិតាមិនដាក់ទោសនរណាឡើយ គឺព្រះអង្គបានប្រគល់អំណាចដាក់ទោសទាំងអស់អោយព្រះបុត្រាវិញ" (គម្ពីរយ៉ូហាន ៥:២២) ។ បទគម្ពីរខាងក្រោមនេះ ផ្តល់ឲ្យយើងនូវចំណេះដឹងបន្ថែម អំពីវិសាលភាពនៃសិទ្ធិក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់៖ គម្ពីរម៉ាថាយ ២៥:៣១-៤៦ គម្ពីរកិច្ចការ ១០:៤២;១៧:៣១ និង គម្ពីរ២កូរិនថូស ៥:១០។

ព្រះយេស៊ូបានប្រើប្រាស់សិទ្ធិទាំងអស់នេះ ហើយនឹងសិទ្ធិដទៃទៀតរបស់ទ្រង់ ដោយគ្មានភាពស្ទាក់ស្ទើរសោះឡើយ។ បើទ្រង់បានប្រើប្រាស់សិទ្ធិទាំងនេះ ដោយទ្រង់មិនមែនជាព្រះជាម្ចាស់ នោះច្បាស់ជាទង្វើឥតកោតក្រែង (ហួសពីអ្វីដែលជារឿងត្រឹមត្រូវ) និង ជាការប្រមាថ។

## *លំហាត់អនុវត្តន៍*

៤ ចូររៀបរាប់ដោយប្រើការចងចាំរបស់អ្នក នូវអ្វីដែលព្រះយេស៊ូបានធ្វើនៅក្នុងអំឡុងពេល ដែលទ្រង់មានព្រះជន្មគង់នៅលើផែនដី ដែលបង្ហាញថាទ្រង់បានប្រើប្រាស់សិទ្ធិជាព្រះជាម្ចាស់របស់ទ្រង់។ ចូរសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

# លក្ខណសម្បត្តិជាព្រះជាម្ចាស់

**វត្ថុបំណងទី៣.** *រៀបរាប់គុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិ ដែលបង្ហាញថាព្រះយេស៊ូជាព្រះជាម្ចាស់។*

## គុណលក្ខណៈខាងសីលធម៌

លក្ខណសម្បត្តិរបស់ព្រះយេស៊ូធ្វើឲ្យមនុស្សងឿងឆ្ងល់។ ពួកគេបានស្ទង់ស្ទែង នឹងអាកប្បកិរិយា និង គុណលក្ខណៈរបស់ទ្រង់នៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ការឆ្លើយតបរបស់ទ្រង់ទៅនឹងស្ថានភាពនៅក្នុងជីវិត បានបង្ហាញយ៉ាងច្បាស់ថាទ្រង់មិនដូចគេនោះទេ។ ទ្រង់មានគុណលក្ខណៈខាងឯសីលធម៌ និង ធម្មជាតិ ដូចជាព្រះជាម្ចាស់ព្រះវរបិតារបស់ទ្រង់។

ព្រះយេស៊ូបានរស់នៅក្នុងជីវិតវិសុទ្ធដ៏ល្អប្រសើរ ដល់ថ្នាក់អ្នកដែលជិតស្និទ្ធទ្រង់ និយាយថា៖ "ព្រះអង្គពុំដែលបានប្រព្រឹត្តអំពើបាបសោះ ហើយក៏ពុំដែលមានព្រះបន្ទូលវៀចវេរណា ចេញពីព្រះឱស្ឋរបស់ព្រះអង្គឡើយ។" (គម្ពីរ១ពេត្រុស ២:២២)។ សត្រូវរបស់ទ្រង់ មិនអាចអះអាងថាទ្រង់មានបាបបានឡើយ ព្រោះទ្រង់គ្មានបាបសោះ (គម្ពីរយ៉ូហាន៨:៤៦)។ គ្មានមនុស្សធម្មតាម្នាក់ណា អាចមានឥរិយាបថកម្រិតនេះបានឡើយ ប៉ុន្តែព្រះយេស៊ូទ្រង់លើសពីមនុស្សទៅទៀត។

*សេចក្ដីស្រឡាញ់* របស់ទ្រង់ ក៏បានកំណត់ព្រះយេស៊ូឲ្យដាច់ពីមនុស្សសាមញ្ញ។ ទ្រង់បានបង្ហាញពីសេចក្ដីស្រឡាញ់របស់ទ្រង់ តាមរយៈទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងមនុស្ស ពីគ្រប់ដំណើរជីវិត និង គ្រប់កម្រិតក្នុងសង្គមទាំងអស់ (គម្ពីរលូកា ១៩:១០ ព្រមទាំងប្រៀបធៀបរវាង គម្ពីរម៉ាថាយ១១:១៩ ជាមួយនឹង គម្ពីរម៉ាកុស ១០:១៧-២២)។ ទ្រង់បានអធិស្ឋានសម្រាប់អ្នកដែលដើរតាមទ្រង់ ហើយទ្រង់ក៏អធិស្ឋានសម្រាប់សត្រូវរបស់ទ្រង់ដែរ (គម្ពីរយ៉ូហាន ១៧:៩-២០ គម្ពីរលូកា ២៣:៣៤)។គុណសម្បត្តិដ៏ឥតខ្ចោះរបស់ទ្រង់មួយនេះបានបង្ហាញថា ទ្រង់គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់។

សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ បានសំដែងទៅតាមរបៀបជាច្រើន។ ទ្រង់បង្ហាញពីការបន្ទាបខ្លួន និង ការដាក់ខ្លួនដ៏ពិត។ នៅពេលដែលទ្រង់បានចូលទៅក្នុងព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់ ទ្រង់បានទទួលការជំរុញចិត្តពីបំណងព្រះហឫទ័យនៃការបម្រើ (គម្ពីរម៉ាថាយ ២០:២៨)។ ក្នុងនាមទ្រង់ជាម្ចាស់ និង ជាគ្រូបង្រៀនម្នាក់ ទ្រង់បានបង្ហាញពីអត្ថន័យពិត នៃការបម្រើតាមរយៈការលាងជើងឲ្យពួកសិស្សរបស់ទ្រង់ (គម្ពីរយ៉ូហាន១៣:១៤) ។ ទ្រង់ទន់ភ្លន់ចំពោះពួកអ្នកមានបាប (គម្ពីរលូកា ៧:៣៧-៣៩, ៤៥-៥០) ចំពោះពួកអ្នកមានចិត្តសង្ស័យ (គម្ពីរយ៉ូហាន ២០:២៩) និង ចំពោះអស់អ្នកដែលបានបដិសេធមិនទទួលស្គាល់ទ្រង់ (គម្ពីរលូកា២២:៦១ គម្ពីរយ៉ូហាន ២១:១៥-២៣)។ ដោយក្ដីស្រឡាញ់ ទ្រង់បានបង្ហាញពីគោលការណ៍ដែលទ្រង់បានបង្រៀន! គ្មានមនុស្សសាមញ្ញណាម្នាក់អាចរស់នៅក្នុងជីវិតដែលពេញដោយសេចក្ដីស្រឡាញ់យ៉ាងពេញបរិបូរណ៍ដូច្នេះបានឡើយ។

សេចក្ដីស្រឡាញ់របស់ទ្រង់ ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់បំផុត តាមរយៈក្ដីស្រឡាញ់ដែលទ្រង់មានចំពោះព្រះជាម្ចាស់ព្រះវរបិតារបស់ទ្រង់។ ទ្រង់បានបង្ហាញ តាមរយៈឧទាហរណ៍ផ្ទាល់របស់ទ្រង់ ថាជីវិតខាងឯវិញ្ញាណដ៏មានប្រសិទ្ធិភាព គឺផ្អែកទៅលើការមានទំនាក់ទំនងយ៉ាងស្និទ ជាមួយព្រះជាម្ចាស់។ គ្មានមនុស្សសាមញ្ញណាម្នាក់អាច អធិស្ឋានដូចជាទ្រង់បានឡើយ។ ទ្រង់បានអធិស្ឋានយ៉ាងស្វិតស្វាញ (គម្ពីរលូកា២២:៣៩-៤៤) យ៉ាងទៀងទាត់ និង យ៉ាងយូរទៀតផង ។ ពេលខ្លះទ្រង់អធិស្ឋានអស់ពេញមួយយប់ ។ មានពេលខ្លះទៀត ទ្រង់តើនឡើងពីព្រលឹមដើម្បីអធិស្ឋាន (គម្ពីរម៉ាកុស ១:៣៥) ។ ទ្រង់បានបន្សល់ទុកគំរូដ៏ល្អឥតខ្ចោះ អំពីមាគ៌ាក្នុងការរក្សា និង អភិវឌ្ឍជីវិតខាងឯវិញ្ញាណរបស់យើង (គម្ពីរ១ពេត្រុស ២:២១)។

គ្មាននរណាម្នាក់ ដែលជិតស្និទជាមួយទ្រង់ អាចសង្ស័យនឹងភាពជាមនុស្សរបស់ទ្រង់បានឡើយ។ ហើយក៏គ្មាននរណាម្នាក់អាចប្រៀបធៀបភាពល្អឥតខ្ចោះរបស់ទ្រង់ ទៅជាមួយនឹងការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់មនុស្សណាម្នាក់បានដែរ។ ឧទាហរណ៍ដ៏ល្អបំផុត អំពីភាពវិសុទ្ធ និង សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ត្រូវបានបង្ហាញឲ្យឃើញនៅក្នុងប្រសាសន៍របស់លោកពេត្រុសថា " លោកជាព្រះគ្រិស្ត(មេស្ស៊ី)* ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ" (គម្ពីរម៉ាថាយ១៦:១៦)។

## *លំហាត់អនុវត្តន៍*

៥ ចូរថ្លែងពីរបៀបដែលព្រះយេស៊ូបង្ហាញពីភាពវិសុទ្ធ និង សេចក្ដីស្រឡាញ់របស់ទ្រង់ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

## គុណលក្ខណៈបែបធម្មជាតិ

លោកប៉ូលបានថ្លែងប្រកាសថា ព្រះយេស៊ូគ្រិស្ដគឺជាឫទ្ធានុភាព និង ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ (គម្ពីរ១កូរិនថូស ១:២៤) ហើយថ្លែងថា ព្រះជាម្ចាស់គាប់ព្រះហឫទ័យឲ្យគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គស្ថិតនៅក្នុងព្រះបុត្រា (គម្ពីរកូឡូស ១:១៩; ២:៩)។ លោកម៉ាថាយបានធ្វើការបញ្ចប់កំណត់ត្រាដំណឹងល្អរបស់លោក ជាមួយនឹងព្រះបន្ទូលរបស់ព្រះយេស៊ូថា ៖ "ខ្ញុំបានទទួលគ្រប់អំណាច [ឫទ្ធានុភាព] ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី" (គម្ពីរម៉ាថាយ ២៨:១៨)។ បទគម្ពីរនេះបានបង្ហាញថាព្រះយេស៊ូដែលជាអង្គទីពីរនៅក្នុងព្រះត្រៃឯក ទ្រង់គឺ*សព្វានុភាព*។ រាល់ទេវតា អំណាច និងឫទ្ធានុភាព នៅក្នុងសាកលលោកនេះ គឺស្ថិតក្រោមឥទ្ធិពលនៃឫទ្ធានុភាព និង សិទ្ធិអំណាចរបស់ទ្រង់ (គម្ពីរ១ពេត្រុស ៣:២២)។

ព្រះគម្ពីរក៏បានបង្រៀនយើងថា ព្រះយេស៊ូទ្រង់*សព្វជ្ញភាព* (មានវត្តមាននៅគ្រប់ទីកន្លែង)។ លោកប៉ូលនិយាយថា ព្រះជាម្ចាស់ព្រះវរបិតាបានដាក់ឲ្យអ្វីសព្វសារពើ នៅក្រោមព្រះរាជបុត្រា និង និយាយថា ព្រះរាជបុត្រា "ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់" (គម្ពីរអេភេសូ ១:២២-២៣ នៅគម្ពីរបកប្រែចាស់)។ នេះពិតជាការលើកទឹកចិត្តដ៏ប្រពៃមួយសម្រាប់យើង នៅពេលដែលយើងចាំថា ទ្រង់នឹងរក្សាព្រះបន្ទូលសន្យារបស់ទ្រង់ ថានឹងគង់នៅជាមួយយើង នៅពេលណាដែលយើងគ្រាន់តែមានគ្នាពីរបីនាក់មករួមគ្នាថ្វាយបង្គំទ្រង់យ៉ាងដូច្នេះ (គម្ពីរម៉ាថាយ ១៨:២០)។ ទោះបីជាមានពេលខ្លះ យើងប្រហែលជាមិនអាចទទួលអារម្មណ៍ដឹងពីព្រះវត្តមានរបស់ទ្រង់ ក៏យើងនៅតែអាចប្រាកដក្នុងចិត្តថា ទ្រង់គឺនៅជាមួយយើងគ្រប់ពេលវេលា!

ព្រះយេស៊ូគ្រិស្ដទ្រង់*សព្វញ្ញុតភាព*(សព្វញ្ញុតញាណ) ទ្រង់ជ្រាបដឹងគ្រប់ការទាំងអស់ (គម្ពីរយ៉ូហាន ២:២៤-២៥;១៦:៣០; ២១:១៧)។ លោកប៉ូលនិយាយអំពីអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ដោយលោកនិយាយថា គឺជាព្រះគ្រិស្ដ "ដែលមានគ្រប់ទាំងផលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្ដីចេះដឹង" (គម្ពីរ

កូឡូស ២:២-៣ នៅគម្ពីរបកប្រែចាស់ ។សូមសង្កត់បញ្ជាក់លើឃ្លាអក្សរទ្រេត)។ ទ្រង់ជ្រាបដឹងអំពីជីវិតមានបាបទាំងប៉ុន្មាន របស់ស្ត្រីសាសន៍សាម៉ារី (គម្ពីរយ៉ូហានជំពូក៤) ទ្រង់ជ្រាបដឹងពីគំនិតរបស់ពួកគណផារ៉ាស៊ី (គម្ពីរលូកា ៦:៨) ទ្រង់ជ្រាបដឹងពីរបៀប និង ពេលណាដែលទ្រង់អាចនឹងចាកចេញពីពិភពលោក (គម្ពីរយ៉ូហាន ១២:៣៣; ១៣:១) ព្រមទាំងធម្មជាតិ និង ទីបញ្ចប់នៃជំនាន់សព្វថ្ងៃ (គម្ពីរម៉ាថាយ ២៤-២៥ គម្ពីរម៉ាកុស ១៣ គម្ពីរលូកា ២១)

បទគម្ពីរខ្លះ បានបណ្តាលឲ្យយើងពិនិត្យមើលទៅលក្ខណសម្បត្តិនៃសព្វញ្ញូតភាពរបស់ទ្រង់ ឲ្យបានកាន់តែស៊ីជម្រៅថែមទៀត ។ ឧទាហរណ៍ នៅក្នុងគម្ពីរម៉ាថាយ ២៤:៣៦ បានប្រាប់ថា ទ្រង់មិនបានជ្រាបដឹងអំពីថ្ងៃនៃការយាងត្រឡប់មកវិញនោះទេ ហើយលោកម៉ាកុសបានសរសេរថា ព្រះយេស៊ូ បានយាងទៅឯដើមឧទុម្ពរ រំពឹងថានឹងបានឃើញមានផ្លែ តែទ្រង់ទទួលបានការខកព្រះទ័យទៅវិញ (គម្ពីរម៉ាកុស ១១: ១៣)។

នៅត្រង់នេះ មានសារៈសំខាន់ណាស់ដែលយើងត្រូវបញ្ជាក់ថា នៅក្នុងកាលដែលទ្រង់គង់នៅលើផែនដី ឬ កាលដែលទ្រង់ជា*មនុស្ស* ព្រះយេស៊ូបានលះបង់សិទ្ធិរបស់ទ្រង់ក្នុងការប្រើប្រាស់ដោយសេរីនូវលក្ខណសម្បត្តិជាព្រះរបស់ទ្រង់។ ទ្រង់មានបំណងព្រះហឫទ័យជ្រើសរើសមិនប្រើប្រាស់អំណាចជាព្រះជាម្ចាស់របស់ទ្រង់នៅក្នុងពេលនោះទេ។ ទ្រង់មានអំណាច ដែលទ្រង់អាចយកមកប្រើ ដើម្បីប្រោសលោះអង្គទ្រង់ផ្ទាល់បាន ប៉ុន្តែទ្រង់បដិសេធមិនប្រើប្រាស់អំណាចទាំងនោះឡើយ (គម្ពីរ ម៉ាថាយ ២៦:៥២-៥៤) ។ ទ្រង់ធ្វើយ៉ាងដូច្នេះ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ ដ្បិតទ្រង់ជ្រាបថាប្រសិនបើទ្រង់ មិនលះបង់ដើម្បីរងទុក្ខ ហើយសុគតនោះទេ ទ្រង់មិនអាចបំពេញបេសកកម្មរបស់ទ្រង់ក្នុងការសុគតជួសមនុស្សជាតិដែលពោរពេញដោយបាបនេះបានឡើយ។ ប៉ុន្តែឥឡូវនេះ ដោយសារបេសកកម្មរបស់ទ្រង់បានសម្រេចហើយ ទ្រង់បានទទួលលក្ខណសម្បត្តិជាព្រះជាម្ចាស់ទាំងអស់របស់ទ្រង់មកវិញ រួមទាំងគុណលក្ខណៈនៃការជ្រាបដឹងគ្រប់ការទាំងអស់ផងដែរ។

ព្រះគម្ពីរបង្ហាញពីព្រះយេស៊ូ ថាជាបុត្រដ៏*អស់កល្បជានិច្ច* របស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១:១ គម្ពីរ១យ៉ូហាន ១:១ គម្ពីរមីកា ៥:២) ។ ទ្រង់មានព្រះជន្មគង់នៅជាដរាបរៀងមក ហើយទ្រង់នឹងគង់នៅជារៀងរហូត (គម្ពីរហេប្រឺ ១:១១-១២;១៣:៨)។ បទគម្ពីរទាំងនេះ ក៏បានប្រកាសថា ព្រះយេស៊ូគ្រិស្ត *មិនដែលប្រែប្រួល* ។ លក្ខណសម្បត្តិដែលយើងបានឃើញទាំងអស់នេះ គឺជាគុណលក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់។ ដូច្នេះហើយ លក្ខណសម្បត្តិទាំងនេះផ្តល់ឲ្យយើងនូវភស្តុតាងយ៉ាងច្បាស់ អំពីភាពជាព្រះរបស់ព្រះយេស៊ូគ្រិស្ត។

# លំហាត់អនុវត្តន៍

៦ សរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយពីមូលហេតុដែលព្រះយេស៊ូមិនប្រើប្រាស់លក្ខណសម្បត្តិជាព្រះជាម្ចាស់របស់ទ្រង់ នៅពេលដែលទ្រង់ជាមនុស្ស ។

៧ ចូរសរសេរនៅចំណងជើង *គុណលក្ខណៈខាងឯសីលធម៌របស់ព្រះយេស៊ូ* និង *គុណលក្ខណៈខាងឯធម្មជាតិរបស់ព្រះយេស៊ូ* ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ចូរសរសេរជាចំណុចៗ អំពីគុណលក្ខណៈដែលមាននៅក្នុងចំណងជើងនីមួយៗ។ បន្ទាប់មកចូរប្រៀបធៀបចំណុចដែលអ្នកបានសរសេរ ជាមួយនឹងគុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិរបស់ព្រះជាម្ចាស់ដែលយើងបានពិភាក្សាគ្នានៅក្នុងមេរៀនទី១ និង ទី២។ តើការប្រៀបធៀបនេះបង្ហាញអ្វីខ្លះដល់អ្នក?

## ការប្រកាសថាជាព្រះជាម្ចាស់

ព្រះយេស៊ូបានធ្វើការប្រកាសច្បាស់ៗមួយចំនួន ដែលថាទ្រង់ជាព្រះជាម្ចាស់។ នៅល្ងាចមុន ការសុគតរបស់ទ្រង់ ទ្រង់បានអះអាងទៅកាន់ពួកសាវ័ក ឲ្យទទួលយកការប្រកាសទាំងនេះដោយមានមូលដ្ឋានទៅលើកិច្ចការអស្ចារ្យរបស់ទ្រង់ (គម្ពីរយ៉ូហាន ១៤:១១)។ តើការប្រកាសរបស់ទ្រង់ មានអ្វីខ្លះ?

១. ទ្រង់មានព្រះបន្ទូលទៅកាន់ពួកយូដាថា ទ្រង់ និង ព្រះវរបិតាគឺតែមួយ (គម្ពីរយ៉ូហាន ១០:៣០)។
២. នៅពេលដែលព្រះយេស៊ូគង់នៅចំពោះមុខពួកព្រឹទ្ធាចារ្យទទួលការកាត់ទោស ទ្រង់បានប្រកាសម្ដងទៀតថា ទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់ (គម្ពីរលូកា ២២:៧០-៧១ គម្ពីរយ៉ូហាន ១៩:៧)។
៣. ទ្រង់បានអះអាងថា មនុស្សអាចទទួលការសង្គ្រោះបាន តែតាមរយៈទ្រង់តែមួយគត់។ (គម្ពីរយ៉ូហាន១០:៩)
៤. ទ្រង់បានមានព្រះបន្ទូលថា ទ្រង់គឺជាផ្លូវតែមួយគត់ដើម្បីចូលទៅឯព្រះវរបិតា (គម្ពីរយ៉ូហាន ១៤:៦)។
៥. ទ្រង់បានមានព្រះបន្ទូលថា គ្មាននរណាម្នាក់អាចធ្វើអ្វីបានឡើយ បើគ្មានការជួយពីទ្រង់នោះ (គម្ពីរយ៉ូហាន ១៥:៥)។
៦. ក្នុងអំឡុងពេល ព័ន្ធកិច្ចនៃការបង្រៀនរបស់ទ្រង់ ទ្រង់បានបញ្ជាក់ពីបុរេអត្ថិភាពរបស់ទ្រង់ (គម្ពីរយ៉ូហាន ៨:៥៨; ១៧:៥)។
៧. ទ្រង់បានបង្គាប់ឲ្យ ពួកសាវ័ករបស់ទ្រង់ អធិស្ឋាននៅក្នុងព្រះនាមរបស់ទ្រង់ (គម្ពីរយ៉ូហាន ១៦:២៣)។
៨. នៅពេលដែលទ្រង់ចាត់បញ្ជូន សាវ័ករបស់ទ្រង់ឲ្យចេញទៅធ្វើព័ន្ធកិច្ច ទ្រង់បានប្រទានឲ្យពួកគេនូវឫទ្ធានុភាព ដើម្បីសំដែងការអស្ចារ្យ (គម្ពីរលូកា ៩:១-២)។

ព្រះបន្ទូល និង ការថ្លែងប្រកាសទាំងអស់នេះ បូករួមទាំងកិច្ចការអស្ចារ្យដែលព្រះយេស៊ូបានសំដែង បានផ្ដល់ឲ្យនូវភស្តុតាងយ៉ាងជាក់ច្បាស់ ដែលបញ្ជាក់ពីការអះអាងរបស់ទ្រង់ថាជាព្រះជាម្ចាស់។

# ព្រះនាមដែលបង្ហាញពីភាពជាព្រះ

ព្រះនាមដែលអាចប្រើប្រាស់ តែដើម្បីសំដៅទៅលើព្រះជាម្ចាស់ ត្រូវបានយកទៅហៅព្រះយេស៊ូគ្រិស្ត នៅទូទាំងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី។ អ្នកនិពន្ធដែលបានជំរុញចិត្តដោយព្រះវិញ្ញាណ តែងតែសរសេរសំដៅទៅរកទ្រង់ថា *ព្រះបុត្រារបស់ព្រះជាម្ចាស់*។ សម្លេងដែលមកពីស្ថានបរមសុខ នៅក្នុងព្រឹត្តិការណ៍ពីរផ្សេងគ្នា បានប្រកាសថាទ្រង់គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់ (គម្ពីរម៉ាថាយ ៣:១៧;១៧:៥)។ ព្រះយេស៊ូក៏បានប្រើប្រាស់ ព្រះនាមនេះដើម្បីហៅអង្គទ្រង់ផងដែរ (គម្ពីរយ៉ូហាន ១០:៣៦)។

ព្រះនាមមួយផ្សេងទៀតដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់ គឺត្រូវបានទស្សន៍ទាយដោយលោកហោរាអេសាយ និង បន្តប្រើម្តងហើយម្តងទៀត ដោយទេវតាដែលបាននិយាយជាមួយនឹងលោកយ៉ូសែប (គម្ពីរអេសាយ ៧:១៤ គម្ពីរម៉ាថាយ ១:២២-២៣)។ បុត្រនោះត្រូវហៅព្រះនាមថា *អេម៉ាញូអែល* ដែលមានន័យថា "ព្រះជាម្ចាស់គង់ជាមួយយើង" (គម្ពីរម៉ាថាយ ១:២៣)។ ព្រះជាម្ចាស់បានយាងមកគង់នៅមួយរយៈលើផែនដីជាមួយមនុស្សប្រុស ស្រី (គម្ពីរយ៉ូហាន ១:១៤)។

លោកយ៉ូហានបានសរសេរថាព្រះយេស៊ូ គឺជា*ព្រះបន្ទូល*របស់ព្រះជាម្ចាស់។ សម្រាប់យើង វាហាក់បីដូចជា នាមមួយចម្លែកណាស់ ប៉ុន្តែនៅជំនាន់នោះ អ្នកទស្សនវិទូ មានទស្សនៈថា គេអាចបូកបញ្ចូលគ្នានូវមូលហេតុ និង ឫទ្ធានុភាព ដែលនៅពីក្រោយបង្កើតសាកលលោកទាំងមូល នៅក្នុងគំនិតអំពីពាក្យពេចន៍ (ព្រះបន្ទូល)។ ដូច្នេះ លោកយ៉ូហាននិយាយថា "ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា" (គម្ពីរយ៉ូហាន ១:១៤)។ ពាក្យសំដីរបស់មនុស្សម្នាក់បង្ហាញពីអ្វីដែលគាត់គិត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់ ដែលបង្ហាញតាមរបៀបដែលយើងអាចយល់បាន។ ព្រះជាម្ចាស់មិនដាច់ចេញពីស្នាព្រះហស្តរបស់ទ្រង់នោះទេ ទ្រង់បង្ហាញអង្គទ្រង់ឲ្យពួកគេបានមើលឃើញវិញ។ លោកយ៉ូហានប្រកាសថា ព្រះបន្ទូល (ព្រះយេស៊ូ) គឺជាព្រះជាម្ចាស់តាំងពីដើមរៀងមក (គម្ពីរយ៉ូហាន ១:១-២)។

ព្រះយេស៊ូក៏ត្រូវបានគេហៅថា *ព្រះជាម្ចាស់* ។ លោកប៉ុលបានសរសេរថាយើង "ទន្ទឹងរង់ចាំសុភមង្គល តាមសេចក្តីសង្ឃឹមរបស់យើង ហើយរង់ចាំព្រះយេស៊ូគ្រិស្តជាព្រះជាម្ចាស់ដ៏ឧត្តមបំផុត និងជាព្រះសង្គ្រោះនៃយើង យាងមកប្រកបដោយសិរីរុងរឿង។" (គម្ពីរទីតុស ២:១៣)។

ព្រះនាមជាភាសាហេប្រឺ *មេស៊ី* តែងតែយកទៅប្រើប្រាស់ទាក់ទងទៅនឹងព្រះយេស៊ូ។ ព្រះនាមដូចគ្នានេះ ជាភាសាក្រិក គឺ *គ្រិស្ត*។ ការបកប្រែមួយទៀត នៃព្រះនាមនេះគឺ *អ្នកដែលគេចាក់ប្រេងអភិសេក*។ តើអ្នកដែលត្រូវគេចាក់ប្រេងអភិសេក មានន័យយ៉ាងដូចម្តេច សម្រាប់ប្រជាជនអ៊ីស្រាអែល? នៅក្នុងវប្បធម៌របស់ពួកគេ នៅពេលដែលព្រះជាម្ចាស់ ត្រាស់ហៅមនុស្សណាម្នាក់ ឲ្យធ្វើកិច្ចការពិសេសណាមួយ អ្នកនោះនឹងត្រូវបាន*ចាក់ប្រេងអភិសេក*ដោយអ្នកដឹកនាំសាសនា ដែលបានយកប្រេងទៅចាក់បង្ហូរលើក្បាលអ្នកដែលត្រូវបានត្រាស់ហៅនោះ។ នេះគឺជានិមិត្តសញ្ញានៃការផ្តាច់ខ្លួនដើម្បីការបម្រើ។ ប្រជារាស្ត្រហេប្រឺ គឺមានទម្លាប់ជាមួយនឹងព្យាការី បូជាចារ្យ និង ស្តេចដែលត្រូវបានចាក់ប្រេងអភិសេកទៅហើយ។ ដូច្នេះ នៅពេលដែលលោកពេត្រុសប្រកាសថាព្រះយេស៊ូគឺ ព្រះអម្ចាស់ និង ជាព្រះគ្រិស្ត អស់អ្នកដែលស្តាប់លោក បានយល់ពីអ្វីដែលលោកចង់និយាយហើយ (គម្ពីរកិច្ចការ ២:៣៦)។ ការឆ្លើយតបរបស់មនុស្ស

ជាច្រើនពាន់នាក់ បង្ហាញថា ពួកគេទទួលស្គាល់ព្រះយេស៊ូជាព្រះមេស្ស៊ី ឬ ជាអ្នកដែលគេចាក់ប្រេងអភិសេកនោះហើយ។

ព្រះយេស៊ូក៏ត្រូវបានគេហៅថា *ព្រះអម្ចាស់* ។ ពេលខ្លះព្រះនាមមួយនេះ ត្រូវបានប្រើប្រាស់ជានាមនៃភាពគួរសម ប៉ុន្តែជាច្រើនលើកច្រើនសា ព្រះនាមនេះត្រូវបានគេប្រើប្រាស់ ដើម្បីសម្តែងការគោរព ចំពោះភាពជាព្រះរបស់ទ្រង់។ (ចូរមើល គម្ពីរលូកា ១:៤៣; ២:១១ គម្ពីរយ៉ូហាន ២០:២៨ គម្ពីរកិច្ចការ ១៦:៣១ និង គម្ពីរ១កូរិនថូស ១២:៣)។ ព្រះនាមនេះ ដែលតែងតែប្រើនិយាយថា ព្រះអម្ចាស់នៃយើង គឺមកពីការបកប្រែពាក្យភាសាហេប្រឺថា *យេហូវ៉ា* ។ ដូច្នេះ ព្រះគ្រិស្តដែលជាព្រះមេស្ស៊ី គឺត្រូវគេហៅ ព្រះយេហូវ៉ា នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់។

## *លំហាត់អនុវត្តន៍*

---

៨ ចូរសរសេរព្រះនាមដែលបានថ្វាយទៅកាន់ព្រះយេស៊ូ ដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់ ព្រមទាំងសរសេរខគម្ពីរដែលជាភស្តុតាងសម្រាប់ព្រះនាមនីមួយៗ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ។ ភាពជាព្រះរបស់ព្រះយេស៊ូ គឺត្រូវបានបង្ហាញតាមរយៈ

ក) ការទទួលបានការថ្វាយបង្គំពីមនុស្ស ការអត់ទោសបាប ការមានព្រះជន្មរស់ឡើងវិញ និង ការទទួលបានសិទ្ធិក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់។

ខ) គុណលក្ខណៈខាងឯសីលធម៌ ដែលមានភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ទ្រង់។

គ) គុណលក្ខណៈខាងឯធម្មជាតិ ដែលមានសព្វានុភាព សព្វដ្ឋភាព សព្វញ្ញុតភាព និង ភាពអស់កល្បជានិច្ចរបស់ទ្រង់។

ឃ) ឥរិយាបថដែលប្រជារាស្ត្ររបស់ទ្រង់ទទួលយកទ្រង់។

ង) ការអះអាងទាមទារភាពជាព្រះរបស់ទ្រង់ផ្ទាល់។

ច) ព្រះនាមរបស់ទ្រង់ដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់។

# គ. ការរួមមកតែមួយនៃភាពជាព្រះ និង ភាពជាមនុស្សនៅក្នុងព្រះគ្រិស្ត

គោលលទ្ធិនៃការចាប់បដិសន្ធិ (ចាប់ជាតិ) ជាបញ្ហាមួយដែលនៅតែមិនអាចដោះស្រាយបាននៅក្នុងក្រុមជំនុំជំនាន់មុន។ គោលលទ្ធិនៃព្រះត្រៃឯក បានចាក់ឫសយ៉ាងរឹងមាំនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ បទពិសោធរបស់មិត្តសម្លាញ់របស់ព្រះយេស៊ូ និង សំណេរដែលមានព្រះវិញ្ញាណជំរុញ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី។ ប៉ុន្តែសំណួរដែលនាំឲ្យមានការប៉ាន់ស្មានយ៉ាងស្រពិចស្រពិល នោះគឺ៖ តើអាចទៅរួចទេ ព្រះបុត្រដែលគង់នៅអស់កល្បជានិច្ចមានឋានៈជាព្រះជាម្ចាស់ស្មើនឹងព្រះវរបិតា មានសមាសភាពដូចព្រះវរបិតា មកចាប់កំណើតជាមនុស្សបាន?

អ្នកខ្លះដែលព្យាយាមបកស្រាយការចាប់បដិសន្ធិ(ចាប់ជាតិ) តែងតែសង្កត់ន័យទៅលើភាពជាមនុស្សរបស់ព្រះយេស៊ូខ្លាំងពេក ដែលគេបែរជាមិនទទួលស្គាល់ភាពជាព្រះរបស់ទ្រង់។ មានអ្នកខ្លះទៀតធ្វើផ្ទុយពីនេះវិញ ដោយពួកគេសង្កត់ន័យតែទៅលើភាពជាព្រះរបស់ទ្រង់ រហូតដល់ចំណុចមួយដែលគេស្ទើតែបដិសេធភាពជាមនុស្សរបស់ទ្រង់ទៅវិញ។ នៅពេលមួយ អ្នកដឹកនាំក្រុមជំនុំជំនាន់នោះ បានឈានទៅរកការកំណត់អត្ថន័យមួយនៃការចាប់បដិសន្ធិ ដែលមកដល់ពេលនេះនៅតែត្រូវបានចាត់ទុកថា ជាមូលដ្ឋានគ្រឹះនៃជំនឿរបស់គ្រិស្តបរិស័ទ ទាក់ទងនឹងអង្គព្រះយេស៊ូ។

# លក្ខណសម្បត្តិនៃការចាប់បដិសន្ធិ

**វត្ថុបំណងទី៤.** *ពិភាក្សាអំពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងការចាប់បដិសន្ធិ។*

អត្ថន័យនៃការចាប់បដិសន្ធិ ត្រូវបានកំណត់ដោយអ្នកដឹកនាំក្រុមជំនុំដំបូង នៅក្នុងការប្រជុំមួយ ដែលហៅថា កិច្ចប្រជុំក្រុមកាល់សេដូន ក្នុងឆ្នាំ៤៥១ គ.ស ដូចតទៅនេះ៖

ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង គឺពិតជាព្រះជាម្ចាស់ ហើយក៏ពិតជាមនុស្ស ដែលមានសារធាតុ ដូចជាព្រះវរបិតានៅក្នុងគ្រប់អ្វីៗទាំងអស់ បើនិយាយពីភាពជាព្រះរបស់ទ្រង់ ហើយក្នុងភាពជាមនុស្សរបស់ទ្រង់ ទ្រង់ដូចជាយើងរាល់គ្នាគ្រប់ផ្នែកទាំងអស់ លើកលែងតែអំពើបាបប៉ុណ្ណោះ។ ដូច្នេះ ព្រះយេស៊ូត្រូវបានគេស្គាល់ក្នុងនិស្ស័យពីរ៖ និស្ស័យជាព្រះជាម្ចាស់ និង និស្ស័យជាមនុស្ស។ និស្ស័យទាំងពីរនេះ គឺដោយឡែកគ្នា។ ភាពដោយឡែកគ្នានេះ ក៏មិនបានលុបបំបាត់ការរួបរួមរវាងនិស្ស័យទាំងពីរនេះដែរ ប៉ុន្តែលក្ខណៈពិសេសនៃនិស្ស័យនីមួយៗគឺត្រូវរក្សាឲ្យនៅដដែល។

ពិតណាស់ អត្ថន័យនេះមិនបានដកចេញនូវអាថ៌កំបាំងនៃការបដិសន្ធិឡើយ។ ផ្ទុយទៅវិញ គ្រិស្តបរិស័ទទាំងអស់ មានអារម្មណ៍ស្ងប់ស្ងែងដូចជាលោកសាវ័កប៉ូលដែរ៖ "គំរោងការដ៏លាក់កំបាំងនៃការគោរពប្រណិប័តន៍ព្រះជាម្ចាស់នោះធំណាស់ គឺថាៈ ព្រះជាម្ចាស់បានបង្ហាញអោយយើងស្គាល់ព្រះគ្រិស្តក្នុងឋានៈជាមនុស្ស" (គម្ពីរ១ធីម៉ូថេ ៣:១៦)។ យើងនឹងយល់អំពីផ្នត់គំនិតដ៏ពិបាកយល់នេះ កាន់តែច្បាស់នៅពេលយើងពិចារណាអំពីការរួបរួមនៃនិស្ស័យជាមនុស្ស និងនិស្ស័យជាព្រះក្នុងព្រះយេស៊ូ និង អំពីសារៈសំខាន់នៃព្រឹត្តិការណ៍ដ៏វិសេសន៍នេះ ។

នៅពេលយើងនិយាយអំពីនិស្ស័យជាមនុស្ស និង និស្ស័យជាព្រះរបស់ព្រះគ្រិស្ត យើងនិយាយសំដៅទៅលើភាពសំខាន់ ឬ តថភាពសំខាន់អំពីទ្រង់។ នៅពេលយើងនិយាយថា ព្រះយេស៊ូមាន *និស្ស័យជាព្រះ* យើងចង់បានន័យថា គុណសម្បត្តិ លក្ខណៈ ឬ គុណលក្ខណៈទាំងអស់ដែលមនុស្សម្នាក់អាចនឹងយកទៅប្រើប្រាស់ដើម្បីរៀបរាប់ពីព្រះជាម្ចាស់ធៀបទៅនឹងព្រះអង្គ(ព្រះយេស៊ូ)។ ដូច្នេះ ទ្រង់គឺជាព្រះជាម្ចាស់ មិនត្រឹមដូចព្រះប៉ុណ្ណោះ តែទ្រង់គឺជាអង្គព្រះជាម្ចាស់ផ្ទាល់តែម្តង។

នៅពេលដែលយើងនិយាយថាព្រះយេស៊ូមាន *និស្ស័យជាមនុស្ស* យើងចង់បានន័យថា ព្រះយេស៊ូគ្រិស្ត មិនមែនជាព្រះជាម្ចាស់ដែលសម្តែងជាមនុស្សនោះទេ ទ្រង់គឺជាមនុស្សតែម្តង។ ទ្រង់មិនត្រឹមតែជាមនុស្ស ឬ ជាព្រះជាម្ចាស់ *ប៉ុណ្ណោះ* នោះទេ ទ្រង់គឺជាព្រះជាម្ចាស់ដែល "កើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា" (គម្ពីរយ៉ូហាន ១:១៤)។ ទ្រង់មិនឈប់ធ្វើជាព្រះជាម្ចាស់នៅពេលដែលទ្រង់ក្លាយជាមនុស្សនោះទេ។ ទ្រង់មិនដោះដូរភាពជាព្រះរបស់ទ្រង់ ជាមួយភាពជាមនុស្សនោះដែរ។ ផ្ទុយទៅ

វិញ ទ្រង់*ចាប់យក*ភាពជាមនុស្ស។ នោះមានន័យថា ទ្រង់បន្ថែមនិស្ស័យជាមនុស្សមួយទៀតទៅលើនិស្ស័យជាព្រះរបស់ទ្រង់។ ដូច្នេះ ដោយសារតែការចាប់បដិសន្ធិនេះហើយ ទ្រង់គឺជាព្រះជាម្ចាស់ផង និង ជាមនុស្សផង យើងហៅថាមនុស្សព្រះក៏បាន។

ព្រះយេស៊ូជាព្រះគ្រិស្តមានគ្រប់ទាំងគុណសម្បត្តិដែលជារបស់មនុស្ស រួមមានខ្លួនប្រាណ និង លក្ខណសម្បត្តិខាងរូបកាយ។ ទោះជាយ៉ាងណា យើងមិនអាចនិយាយថា នៅក្នុងទីជម្រៅរបស់ទ្រង់ ទ្រង់គឺជាមនុស្សម្នាក់នោះទេ។ ទ្រង់គឺជា *ព្រះជាម្ចាស់* ដែលមាននិស្ស័យជាមនុស្ស។ នោះបានន័យថា ទ្រង់មិនដាក់បញ្ចូលបុគ្គលិកលក្ខណៈរបស់មនុស្ស ទៅក្នុងនិស្ស័យរបស់ទ្រង់ផ្ទាល់នោះឡើយ តែផ្ទុយទៅវិញ ទ្រង់បន្ថែមនិស្ស័យជាមនុស្ស ទៅក្នុងបុគ្គលិកលក្ខណៈផ្ទាល់របស់ទ្រង់។ បុគ្គលិកលក្ខណៈជាព្រះជាម្ចាស់របស់ទ្រង់ គឺជាអ្វីដែលនៅទីជម្រៅបំផុត។ ប្រសិនបើទ្រង់មិនមែនជាព្រះជាម្ចាស់នោះទេ ទ្រង់មិនអាចទទួលបានការថ្វាយបង្គំពីយើងបាននោះឡើយ សម្រាប់គ្រិស្តបរិស័ទ គឺត្រូវបានតម្រូវឲ្យថ្វាយបង្គំព្រះជាម្ចាស់តែមួយអង្គគត់។

ដូច្នេះ យើងឃើញថាការចាប់បដិសន្ធិរបស់ព្រះបុត្រា បានរួបរួមភាពជាព្រះជាម្ចាស់ពិត និង ភាពជាមនុស្សដ៏ពិតនៅក្នុងខ្លួនបុគ្គលម្នាក់។ ដូច្នេះ មានការប្រកបនៃគុណសម្បត្តិមួយនៅក្នុងអង្គទ្រង់ដែលយើងអាចនិយាយអំពីទ្រង់តាមរបៀបដែលស័ក្តិសមក្នុងការនិយាយជាមួយព្រះជាម្ចាស់ ឬ មនុស្ស។

## *លំហាត់អនុវត្តន៍*

១០ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលបង្ហាញពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទាក់ទងទៅនឹងការចាប់បដិសន្ធិ។

ក) ព្រះយេស៊ូគ្រិស្តគឺជាអង្គព្រះជាម្ចាស់ដែលចាប់យកភាពជាមនុស្ស។

ខ) ព្រះគ្រិស្តគឺជាមនុស្សដែលចាប់យកភាពជាព្រះ។

គ) ដោយសារព្រះយេស៊ូគ្រិស្តជា អង្គព្រះជាម្ចាស់ ទ្រង់ជាព្រះដែលស័ក្តិសមទទួលបានការថ្វាយបង្គំរបស់យើង។

ឃ) ទាក់ទងទៅនឹងនិស្ស័យជាមនុស្សរបស់ទ្រង់ ព្រះយេស៊ូទ្រង់ចេះឃ្លាន ចេះស្រេក ចេះព្រួយបារម្ភ និង ទទួលការឈឺចាប់ ព្រមទាំងការស្លាប់ដូចគ្នា។ ទាក់ទងទៅនឹងនិស្ស័យជាព្រះរបស់ទ្រង់ ទ្រង់តែងតែសព្វព្រះហឫទ័យធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតាជានិច្ច ដ្បិតទ្រង់ពិតជាព្រះជាម្ចាស់។

## មូលហេតុនៃការចាប់បដិសន្ធិ

នៅក្នុងស្ថានភាពដែលមានកម្រិតរបស់យើង យើងមិនអាចនឹងយល់ពីមូលហេតុដែលព្រះអម្ចាស់មកចាប់កំណើតជាមនុស្សនោះទេ។ តើអ្វីជាកត្តាជំរុញឲ្យព្រះបុត្រារបស់ព្រះជាម្ចាស់យាងមកលើផែនដីមកក្លាយជាផ្នែកមួយនៃអំបូរដែលបានដួលរលំ និង ត្រូវបានហ៊ុំព័ទ្ធដោយក្តីច្រណែន និង ការស្អប់ខ្ពើមយ៉ាងដូច្នេះ?

ដំបូងបំផុត ព្រះជាម្ចាស់មិនអាចសុគតបាននោះទេ។ វាគឺជារឿងចាំបាច់ណាស់ ដែលត្រូវតែមានការបូជាមួយដែលគ្មានទោសកំហុសទាល់តែសោះសម្រាប់អំពើបាប។ ដោយសារមនុស្សជាតិទាំងអស់ មានបាប ព្រះជាម្ចាស់បានយាងមកចាប់កំណើតជាមនុស្សដើម្បី ប្រទានក្នុងបូជាដ៏ឥតខ្ចោះ ដើម្បីបង់លោះសម្រាប់ទោសនៃបាប (គម្ពីរហេព្រើ ២:៩)។ ទីពីរ តាមរយៈការចាប់បដិសន្ធិ ព្រះយេស៊ូបានបង្ហាញព្រះវរបិតាទៅកាន់មនុស្សជាតិ ឲ្យឃើញពីភាពល្អឥតខ្ចោះគ្មានអ្វីប្រៀបផ្ទឹម និង ភាពស្រស់ស្អាតរបស់ព្រះអង្គ (គម្ពីរយ៉ូហាន ១៤:៧-១១)។ ទីបី តាមរយៈការចាប់កំណើតជាមនុស្ស ព្រះអម្ចាស់នៃយើង បានផ្តល់ឲ្យយើងនូវគំរូមួយដ៏ត្រឹមត្រូវ (គម្ពីរ១ពេត្រុស ២:២១-២៥)។ នៅពេលដែលយើងសិក្សាអំពី របៀបដែលទ្រង់ឆ្លើយតបទៅនឹងស្ថានភាពរបស់មនុស្ស យើងអាចត្រូវបានគេសំគាល់ជាមួយទ្រង់ និងដឹងថាគោលដៅរបស់គ្រិស្តបរិស័ទគឺរស់នៅឲ្យបានដូចជាព្រះគ្រិស្ត (គម្ពីររ៉ូម ៨:២៩)។

ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ទ្រង់នឹងចាត់បញ្ជូនពួកគេឲ្យទៅពេញពិភពលោក តាមរបៀបដែលព្រះវរបិតាបានចាត់បញ្ជូលទ្រង់មកដែរ (គម្ពីរយ៉ូហាន ១៧:១៨; ២០:២១)។ ក្រឹត្យវិន័យនេះ មានភ្ជាប់ជាមួយនឹងការថ្លែងប្រកាសពីការប្រទានសេចក្តីសង្រ្គោះរបស់ព្រះជាម្ចាស់ ទៅកាន់មនុស្សគ្រប់រូបដែលជឿលើទ្រង់។ នេះគឺជាផ្នែកមួយនៃមហាបេសកម្ម ក្នុងការចេញទៅក្នុងពិភពលោក ហើយធ្វើការចែកចាយដំណឹងល្អទៅកាន់គ្រប់ស្នាព្រះហស្តរបស់ព្រះជាម្ចាស់ទាំងអស់ (គម្ពីរម៉ាកុស ១៦:១៥)។ ព្រះយេស៊ូ គឺជាការប្រទានរបស់ព្រះជាម្ចាស់ មកសម្រាប់សង្រ្គោះយើងរាល់គ្នា។ យើងត្រូវនាំដំណឹងល្អទៅកាន់មនុស្សគ្រប់គ្នា។

# *លំហាត់អនុវត្តន៏*

---

១១ ចូរសរសេរលេខ១ នៅខាងមុខប្រយោគណា ដែលជាមូលហេតុពិត ឬ ត្រឹមត្រូវនៃការចាប់បដិសន្ធិ ។ សរសេរលេខ២ ប្រសិនបើប្រយោគនោះមិនពិត។

.........ក) ព្រះយេស៊ូត្រូវចាប់កំណើតក្នុងរូបកាយដែលរមែងតែស្លាប់ ដើម្បីទ្រង់អាចបង់លោះទោសស្លាប់សម្រាប់បាបរបស់របស់។

.........ខ) ការចាប់បដិសន្ធិ គឺពិតជាចាំបាច់ណាស់ ព្រោះព្រះជាម្ចាស់ត្រូវតែដឹងថា តើការក្លាយខ្លួនជាមនុស្សមានបាបនោះ យ៉ាងណា?

..........គ) តាមរយៈការចាប់បដិសន្ធិ យើងទទួលបានការបង្ហាញឲ្យឃើញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និង ការផ្គត់ផ្គង់សម្រាប់មនុស្សជាតិ។

..........ឃ) ការចាប់បដិសន្ធិ បានផ្តល់ឲ្យព្រះយេស៊ូនូវ បទពិសោធន៍ផ្ទាល់ នៃភាពមានកម្រិត និង ភាពទន់ខ្សោយរបស់មនុស្សជាតិ។ ការនេះបញ្ជាក់ថាទ្រង់មានសិទ្ធិទូលអង្វរជួសយើង ជាមួយនឹងព្រះវរបិតា។

..........ង) ជាលទ្ធផលដែលបានមកពីការចាប់បដិសន្ធិរបស់ទ្រង់ មនុស្សមិនកើតមកនៅក្នុងអំពើបាបទៀតទេ ដ្បិតការបូជានៃបុត្ររបស់ព្រះជាម្ចាស់ ក្នុងសណ្ឋានជាមនុស្សបានធ្វើឲ្យមនុស្សជាតិអស់ទោសកំហុស។

# ឃ. រាជកិច្ចរបស់ព្រះគ្រិស្ត

**វត្ថុបំណងទី ៥.** *បកស្រាយពីមូលហេតុដែលកិច្ចការរបស់ព្រះគ្រិស្ត ជាសារៈសំខាន់សម្រាប់មនុស្សជាតិ។*

ឥឡូវនេះយើងបែរត្រឡប់ទៅមើលពីរាជកិច្ចរបស់ព្រះគ្រិស្តវិញ។ នៅពេលដែលយើងនិយាយអំពី *រាជកិច្ច*របស់ទ្រង់ យើងសំដៅទៅការសុគត ការមានព្រះជន្មរស់ឡើងវិញ ការឡើងទៅស្ថានបរមសុខ និង ការលើកតម្កើង ព្រះគ្រិស្ត។ យើងនឹងពិចារណាអំពីរាជកិច្ចទាំងនេះ ទៅតាមលំដាប់លំដោយដែលរាជកិច្ចទាំងនេះកើតមានឡើង។

## ការសុគតរបស់ទ្រង់

ការសុគតរបស់ព្រះយេស៊ូ គឺមានលក្ខណៈខុសគ្នាពីការស្លាប់របស់មនុស្សផ្សេងៗទៀត។ ទីមួយ ការសុគតរបស់ទ្រង់ គឺដោយការស្ម័គ្រព្រះទ័យទាំងស្រុង។ ទ្រង់បានមានព្រះបន្ទូលអំពីការសុគតថា "គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្ដូរជីវិត ដោយខ្លួនខ្ញុំផ្ទាល់តែម្ដង។" (គម្ពីរយ៉ូហាន ១០:១៨)។ នៅពេលដែលទ្រង់សុគតទ្រង់បានលះបង់ព្រះវិញ្ញាណរបស់ទ្រង់ (គម្ពីរម៉ាថាយ២៧:៥០)។ ការសុគតនេះមិនធ្វើឡើងដោយមានការបង្ខិតបង្ខំ ពីសាតាំង ឬ ដោយអនុភាពដ៏លើសលប់របស់ពួកទាហានរ៉ូម៉ាំងនោះទេ។ ផ្ទុយវិញ ទ្រង់បានទទួលយកការសុគតនេះ តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីការសង្គ្រោះមនុស្សជាតិវិញ។

ការសុគតរបស់ទ្រង់គឺជារាជកិច្ចមួយ ហើយតាមរយៈការសុគតរបស់ទ្រង់នេះ ព្រះគ្រិស្តបានបង់លោះទោសបាបរបស់យើង។ ទោសនៃអំពើបាប គឺជាការដាច់ចេញពីព្រះជាម្ចាស់។ នេះគឺជាទោសដែលទ្រង់ត្រូវបង់លោះ ដើម្បីការសង្គ្រោះយើង។ នៅពេលដែលទ្រង់សុគតនៅលើឈើឆ្កាង ទ្រង់ទទួលរងការកាត់ផ្ដាច់ដ៏អាក្រក់មួយនេះ។ ទ្រង់ស្រែកទូលថា៖ "ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?" (គម្ពីរម៉ាកុស ១៥:៣៤)។ នៅក្នុងរាជកិច្ចមួយនេះ ទ្រង់រំងាប់ ឬធ្វើឲ្យស្ងប់ ព្រះពិរោធរបស់ព្រះជាម្ចាស់ ដែលបានកើតឡើយដោយសារតែអំពើបាបរបស់យើង។ ទ្រង់បានអនុញ្ញាតិកម្លាំងបោកបក់នៃភាពយុត្តិធម៌ដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ធ្លាក់មកលើទ្រង់។ តាមរយៈការបូជារបស់ទ្រង់ ព្រះគ្រីស្ទបានធ្វើការរំដោះអំពើបាបរបស់យើង ដោយការសុគតរបស់ព្រះអង្គ ដែលជាការជំនួសការស្លាប់របស់យើង។ទ្រង់ធ្វើយ៉ាងដូច្នេះ ដើម្បីឲ្យយើងទទួលបានការលើកលែងទោស និង អាចផ្សះផ្សាឲ្យបានទៅដល់កន្លែងដែលមានភាពស៊ីចង្វាក់គ្នាជាមួយព្រះជាម្ចាស់។

ជាច្រើនសម័យកាលមកហើយ មនុស្សបានព្យាយាមបង្វែរចេញនូវកំហឹងរបស់ព្រះដែលពួកគេ បានបង្កើតឡើង។ ពួកគេពិតជាគួរឲ្យអាណិតខ្លាំងណាស់។ ពួកគេបានថ្វាយដង្វាយ និង ធ្វើការបូជាឈាម ប៉ុន្តែពួកគេបានចាកចេញទៅទាំងមិនបានដឹងថា ដង្វាយរបស់ពួកគេត្រូវបានព្រះរបស់ពួកគេទទួលបានហើយឬនៅ។ ឧទាហរណ៍ជនជាតិភាគតិច អាហ្សតិច មានការកោតខ្លាចយ៉ាងខ្លាំងចំពោះអ្វីដែលពួកគេគិតថាជាព្រះរបស់ពួកគេ។ ពួកគេថ្វាយមនុស្សជាច្រើនដើម្បីធ្វើជាយញ្ញបូជា នៅពេលដែលពួកគេគិតថាជារឿងចាំបាច់ ប៉ុន្តែអំពើល្អ ដ៏មានតម្លៃ និង ពេញដោយការគោរពនេះ គឺតែងតែឥត

ន័យ។ ការឆ្លើយតបរបស់អាចារ្យពួកគេ នៅតែឆ្លើយតបដដែលថាៈ "ព្រះរបស់យើងទាមទារ ឈាមបន្ថែមទៀត"!

ព្រះគម្ពីរបានបង្ហាញប្រាប់យើងថា ព្រះវរបិតានៃស្ថានបរមសុខរបស់យើង ទ្រង់ពិតជាក្រោធខ្លាំងណាស់ ព្រោះអំពើបាបរបស់យើង ប៉ុន្តែព្រះពិរោធរបស់ទ្រង់គឺមិនដូចជាគំនិតរបស់ជនជាតិអាហ្សតិច ដែលគិតអំពីព្រះរបស់ពួកគេឡើយ។ យើងមិនមានភាពភ័យខ្លាច ឬ និស្ស័យទាក់ទងទៅនឹង អ្វីដែលយើងត្រូវធ្វើ ដើម្បីបំបាត់ព្រះពិរោធរបស់ទ្រង់ឡើយ។ ទ្រង់បានធ្វើការនោះដោយអង្គទ្រង់ហើយ។ ទ្រង់បានប្រទានការបូជារបស់ព្រះអង្គផ្ទាល់ គឺព្រះបុត្រារបស់ព្រះអង្គ។ តាមរយៈការសុគតរបស់ទ្រង់ ព្រះយេស៊ូបានបង់លោះទោសកំហុស និង ធ្វើឲ្យអ្វីបានទៅជាល្អប្រសើរវិញ។ ដោយធ្វើយ៉ាងដូច្នេះ សេចក្ដីសុចរិតរបស់ព្រះជាម្ចាស់ បានរក្សាទុកនៅ។ អំពើបាបត្រូវបានដោះស្រាយ ទោសកំហុសត្រូវបានបង់លោះ មនុស្សទទួលបានការអត់ទោស ហើយមានសិទ្ធិចូលទៅកាន់ព្រះជាម្ចាស់ដ៏វិសុទ្ធ។ លោកប៉ូលបានបកស្រាយការនេះ នៅក្នុងគម្ពីររ៉ូម៣:២៥-២៦ៈ

> ព្រះជាម្ចាស់បានតំរូវអោយព្រះយេស៊ូធ្វើជាយញ្ញបូជា សំរាប់លោះអស់អ្នកដែលមានជំនឿ អោយរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គ។ ធ្វើដូច្នេះ ព្រះអង្គបង្ហាញរបៀបដែលព្រះអង្គប្រោសមនុស្សអោយបានសុចរិត គឺពីដើម ព្រះអង្គពុំបានដាក់ទោសមនុស្សលោកដែលប្រព្រឹត្តអំពើបាប ក្នុងគ្រាដែលព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ដល់គេនោះទេ។ ឥឡូវនេះ ព្រះអង្គសព្វព្រះហឫទ័យបង្ហាញអំពីរបៀបដែលព្រះអង្គប្រោសមនុស្សអោយបានសុចរិត ដើម្បីសំដែងថាព្រះអង្គសុចរិត ហើយទ្រង់ប្រោសអ្នកដែលជឿលើព្រះយេស៊ូអោយបានសុចរិតផងដែរ។

ការសុគតរបស់ព្រះគ្រិស្ត ក៏មានផលប្រយោជន៍ជាក់ស្តែងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងដែរ។ នៅក្នុងសំបុត្រមួយរបស់លោកប៉ូល ទៅកាន់ក្រុមជំនុំក្រុងកាឡាទី លោកនិយាយថាៈ "ខ្ញុំបានជាប់ឆ្កាងរួមជាមួយព្រះគ្រិស្ត" (គម្ពីរកាឡាទី២:១៩) ។ "អស់អ្នកដែលរួមជាមួយព្រះគ្រិស្តយេស៊ូបានឆ្កាងតណ្ហា និងបំណងលោភលន់ផ្សេងៗរបស់និស្ស័យលោកីយ៍នោះចោលហើយ។" (គម្ពីរកាឡាទី៥:២៤) ។ ការនេះមានពាក់ព័ន្ធជាមួយនឹងការឆ្កាង*ខ្លួនឯង* ដែលមានន័យថាការលះបង់បំណងចិត្តផ្ទាល់ខ្លួន ដើម្បីបែរទៅធ្វើអ្វីដែលគាប់ព្រះហឫទ័យទ្រង់។ ការជាប់ឆ្កាងរបស់ព្រះគ្រិស្ត ត្រូវក្លាយទៅជាការជាប់ឆ្កាងរបស់យើង។ ការសង្គ្រោះដែលទ្រង់បានប្រទានមក ផ្តល់ឲ្យយើងនូវ ឱកាសដើម្បីរស់នៅក្នុងជីវិតដ៏វិសុទ្ធមួយ ជាជីវិតដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ពិតៗ។ ការនេះនឹងក្លាយទៅជាការពិត នៅពេលយើងថ្វាយជីវិតរបស់យើង ទៅកាន់ភាពជាម្ចាស់របស់ទ្រង់ និង ទៅកាន់ការគ្រប់គ្រងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីររ៉ូម ៨:៥-១១)។

## *លំហាត់អនុវត្តន៍*

១២ តើអ្នកកំពុងធ្វើការដើម្បីសម្លាប់និស្ស័យមានបាបរបស់អ្នកមែនទេ? ចូររៀបរាប់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក អំពីអ្វីដែលអ្នកដទៃអាចឃើញនៅក្នុងអ្នក ដែលបង្ហាញថាអ្នកបានឆ្កាងខ្លួនឯង ហើយបែរទៅផ្ដល់ការយកចិត្តទុកដាក់ទៅលើទំនួលខុសត្រូវជាគ្រិស្តបរិស័ទវិញ។

១៣ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខប្រយោគត្រឹមត្រូវ ទាក់ទងនឹងសារៈសំខាន់នៃរាជកិច្ចរបស់ព្រះគ្រិស្តសម្រាប់យើង។

ក) ការសុគតរបស់ទ្រង់បានបង់ថ្លៃជួសអំពើបាបរបស់យើង ហើយបានរំសាយព្រះពិរោធរបស់ព្រះជាម្ចាស់។

ខ) ការសុគតរបស់ព្រះគ្រិស្ដ គឺជាលទ្ធផលដែលបានមកពីការបង្ខិតបង្ខំនៃអំណាចដែលលើសពីគ្រប់គ្រងរបស់ទ្រង់ ដូច្នេះហើយ ការសុគតនេះគឺគ្រាន់តែជារឿងចៃដន្យមួយប៉ុណ្ណោះ។

គ) ការសុគតរបស់ព្រះគ្រិស្ដបានផ្សះផ្សាសម្ព័ន្ធភាពរវាងព្រះជាម្ចាស់ និង មនុស្សជាតិ។

ឃ) ការសុគតរបស់ទ្រង់បានបំពេញសេចក្ដីយុត្តិធម៌របស់ព្រះជាម្ចាស់ ដែលត្រូវបានបែរឆ្ពោះទៅរកអំពើបាបនៃមនុស្សជាតិ។

ង) ដោយព្រោះការសុគតរបស់ព្រះគ្រិស្ដ យើងនឹងមិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអំពើបាបរបស់យើងទៀតឡើយ ទោះបីជាយើងនៅតែកំពុងបន្តប្រព្រឹត្តិអំពើបាបក៏ដោយ។

ច) ការសុគតរបស់ព្រះគ្រិស្ដ គឺជាគំរូមួយនៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការផ្ដន្ទាទោសយើង ចំពោះភាពទន់ខ្សោយ និង ភាពបរាជ័យជាមនុស្សរបស់យើង។

## ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់

ប្រសិនបើព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ដនៃយើងមិនមានព្រះជន្មរស់ឡើងវិញនោះទេ រាជកិច្ចរបស់ទ្រង់មិនអាចនឹងសម្រេចបាននោះទេ ហើយជំនឿរបស់យើងក៏នឹងមិនមានប្រយោជន៍អ្វីដែរ (គម្ពីរ ១កូរិនថូស ១៥:១៤)។ ព្រឹត្តិការណ៍នេះបានសំគាល់ ពីការសម្រេចនៃរាជកិច្ចរបស់ទ្រង់នៅលើផែនដីនេះ។ ដូច្នេះ ការមានព្រះជន្មរស់របស់ព្រះគ្រិស្ដ បានកំណត់ឲ្យគ្រិស្តបរិស័ទដាច់ចេញទាំងស្រុងពីសាសនា និង ជំនឿទាំងឡាយផ្សេងៗទៀត។ គ្មានសាសនាណាផ្សេង អាចនិយាយបានថាផ្នូររបស់ស្ថាបនិកសាសនារបស់ពួកគេនៅទទេនោះទេ។ យើងរាល់គ្នាដែលជាគ្រិស្តបរិស័ទ មិននាំគ្នាទៅប្រមូលផ្ដុំនៅកន្លែងផ្ទុកសាកសពរបស់ព្រះអម្ចាស់នៃយើងឡើយ ព្រោះទ្រង់មិនគង់នៅក្នុងផ្នូរនោះទេ! យើងសរសើរតម្កើងទ្រង់ទុកជាព្រះអង្គសង្គ្រោះដ៏រស់! ទ្រង់បានឈ្នះសេចក្ដីស្លាប់ហើយ! ដោយព្រោះទ្រង់មានព្រះជន្មរស់ យើងបានស្នងជីវិតដ៏អស់កល្បជានិច្ច។

ការមានព្រះជន្មរស់របស់ព្រះគ្រិស្ដគឺជា ថ្មគ្រឹះនៃជំនឿរបស់គ្រិស្តបរិស័ទ។ បើគ្មានការមានព្រះជន្មរស់របស់ទ្រង់នោះទេ ការសុគតរបស់ព្រះគ្រិស្ដមុខជាគ្មានអត្ថន័យអ្វីឡើយ ដ្បិតការមានព្រះជន្មរស់ បានបង្ហាញពីប្រសិទ្ធិភាពនៃការសុគតរបស់ទ្រង់ និង បានផ្ដល់តម្លៃទៅឲ្យការសុគតនោះផង។ ទាក់ទង

ជាមួយនឹងរឿងនេះ លោកប៉ុលមានប្រសាសន៍ថាៈ "ព្រះជាម្ចាស់ប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ ដើម្បីអោយយើងបានសុចរិត" (គម្ពីររ៉ូម៤:២៥)។

មានមូលហេតុជាច្រើន ដែលការមានព្រះជន្មរស់មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើង។ យើងគប្បីកត់សំគាល់ពីលទ្ធផលពិសេសៗនៃព្រឹត្តិការណ៍នេះ។

១. ការមានព្រះជន្មរស់បង្ហាញថារាជកិច្ចរបស់ព្រះគ្រិស្ត នៃការធ្វើជាអ្នកជំនួសកន្លែងមនុស្សមានបាប ត្រូវបានទទួលយក។ យើងអាចទុកចិត្តបានថា ព្រះជាម្ចាស់បានទទួលយកការសុគតជំនួសរបស់ព្រះគ្រិស្ត ព្រោះ ព្រះជាម្ចាស់បានប្រោសទ្រង់ឲ្យមានព្រះជន្មរស់ឡើងវិញ (គម្ពីរកិច្ចការ ២:២៤, ៣២; ៣:១៥; ៤:១០; ៥:៣០)។

២. ការមានព្រះជន្មរស់ បញ្ជាក់ពីភាពជាព្រះរបស់ព្រះអម្ចាស់។ លោកប៉ុលបានប្រកាសនៅក្នុងគម្ពីររ៉ូម១:៤ ថាៈ "តែបើគិតតាមព្រះវិញ្ញាណ ដែលផ្តល់អោយមនុស្សបានវិសុទ្ធ*វិញ ព្រះជាម្ចាស់បានតែងតាំងព្រះអង្គ ជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព ដោយប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ។"

៣. តាមរយៈគុណសម្បត្តិនៃការមានព្រះជន្មរស់របស់ទ្រង់ ព្រះគ្រិស្តបានក្លាយទៅជា *មហាបូជាចារ្យដ៏ខ្ពង់ខ្ពស់របស់យើង* នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ (គម្ពីរហេប្រឺ ៩:២៤)។ ទ្រង់គឺជាអ្នកសម្រុះសម្រួលរបស់យើង (គម្ពីររ៉ូម ៨:៣៤) ជាអ្នកផ្លូវការរបស់យើងនៅឯស្ថានបរមសុខ (គម្ពីរអេភេសូ ១:២០-២២) ជាអ្នកសម្របសម្រួលរបស់យើង (គម្ពីរ១ធីម៉ូថេ ២:៥) និង អ្នកនិយាយជួស ឬ មេធាវីរបស់យើង (គម្ពីរ១យ៉ូហាន ២:១) ។ ដូច្នេះ បន្ថែមពីលើការប្រោសលោះ ឲ្យផុតពីចំណងទោស ដែលធ្វើឡើងតាមរយៈការសុគតរបស់ទ្រង់ ព្រះគ្រិស្តបានចូលមកទូលអង្វរជួសយើង នៅចំពោះព្រះរាជបល្ល័ង្កនៃព្រះគុណ។

៤. ការមានព្រះជន្មរស់ បង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងការប្រទានការសង្គ្រោះសម្រាប់យើង។ យើងអាចប្រាកដក្នុងចិត្តថា ទ្រង់នឹងផ្គត់ផ្គង់ឲ្យយើងមានអំណាចដែលសមស្របដើម្បីឲ្យយើងមានជីវិតរស់ និង បម្រើទ្រង់យ៉ាងមានប្រសិទ្ធិភាព (ចូរប្រៀបធៀបគម្ពីរភីលីព ៣:១០ ជាមួយនឹងគម្ពីរភីលីព ១:៦)។ ទ្រង់មានឫទ្ធានុភាពគ្រប់ទាំងអស់។

៥. ការមានព្រះជន្មរស់គឺជាការធានា ថាអស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ(គម្ពីរយ៉ូហាន ៥:២៨; ៦:៤០គម្ពីររ៉ូម ៨:១១ គម្ពីរ១កូរិនថូស ១៥:២០-២៣ គម្ពីរ១ថេស្សាឡូនិក៤:១៤)។

ដូច្នេះ ការមានព្រះជន្មរស់ បាននាំឲ្យបេសកម្មនៃការសង្គ្រោះរបស់ព្រះជាម្ចាស់បានបញ្ចប់ទៅយ៉ាងសមស្រប។ បេសកកម្មនេះត្រូវបានរៀបចំផែនការតាំងពីដើមមកហើយ ប៉ុន្តែត្រូវបានអនុវត្តនៅពេលដែលព្រះជាម្ចាស់ពុះផ្តាច់ច្រវ៉ាក់នៃអត្ថិភាពជាមនុស្ស តាមរយៈការចាប់បដិសន្ធិ។ ព្រះគ្រិស្តបានរស់នៅក្នុងជីវិតល្អឥតខ្ចោះ ហើយទ្រង់បានសុគតជាអ្នកជំនួសដ៏ល្អឥតខ្ចោះសម្រាប់មនុស្សបាប ហើយបានបង់លោះទោសបាបរបស់ពួកគេផងដែរ។ ដោយធ្វើយ៉ាងដូច្នេះ ទ្រង់បានពន្លត់ព្រះពិរោធរបស់ព្រះជាម្ចាស់ ផ្សះផ្សាអ្នកមានបាបជាមួយព្រះជាម្ចាស់ និង ស្រោចស្រង់សមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបជាមួយព្រះ

វិញ្ញាណដ៏វិសុទ្ធ។ បន្ទាប់មក រាជកិច្ចរបស់ព្រះគ្រិស្តនៅលើផែនដីបានសម្រេច ហើយក៏ដល់ពេលដែលទ្រង់ត្រូវត្រឡប់ទៅឯព្រះវរបិតាវិញដែរ ។ បេសកកម្មរបស់ទ្រង់បានសម្រេចយ៉ាងជោគជ័យ!

## លំហាត់អនុវត្តន៍

១៤ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខប្រយោគដែលនិយាយពីលទ្ធផលដ៏ពិតប្រាកដនៃការមានព្រះជន្មរស់ឡើងវិញ។

ក) ការមានព្រះជន្មរស់ឡើងវិញ បានធ្វើឲ្យគ្រិស្តសាសនា ជាសាសនាមួយនៅក្នុងចំណោមសាសនានានាដែលមានស្ថាបនិកបានត្រឡប់មកមានជីវិតរស់ឡើងវិញ។

ខ) ការមានព្រះជន្មរស់ឡើងវិញ បង្ហាញពីការទទួលយករបស់ព្រះជាម្ចាស់ នូវការបូជារបស់ព្រះគ្រិស្តទុកជាការលុបលាងទោសសម្រាប់បាបរបស់មនុស្សជាតិ។

គ) ភាពជាព្រះរបស់ព្រះអម្ចាស់នៃយើង បានបញ្ជាក់ដោយការមានព្រះជន្មរស់របស់ទ្រង់។

ឃ) តាមរយៈការមានព្រះជន្មរស់របស់ទ្រង់ ព្រះគ្រិស្តបានក្លាយជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់ ដែលជួយទូលអង្វរជំនួសយើងនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់។

ង) ការមានព្រះជន្មរស់ធានា ថាគ្រិស្តបរិស័ទមិនអាចនឹងធ្លាក់ចេញពីព្រះទ័យមេត្តារបស់ព្រះជាម្ចាស់បានឡើយ។

ច) ការមានព្រះជន្មរស់គឺជាការធានាសម្រាប់អ្នកជឿថា អស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្ត នឹងត្រូវបានប្រោសឲ្យមានជីវិត នៅថ្ងៃទ្រង់យាងត្រឡប់មកវិញ។

## ការលើកឡើងទៅ និង ការលើកតម្កើងរបស់ទ្រង់

កំណត់ត្រានៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី បង្ហាញថា បន្ទាប់ពីធ្វើបេសកកម្មបាន៤០ថ្ងៃ ក្រោយពេលមានព្រះជន្មរស់ឡើងវិញហើយ ព្រះគ្រិស្តត្រូវលើកឡើង ឬ ត្រឡប់ទៅឯស្ថានបរមសុខវិញៈ "នៅពេលដែលក្រុមសាវ័កកំពុងតែមើលព្រះអង្គ នោះព្រះជាម្ចាស់ក៏លើកព្រះអង្គឡើងទៅលើមេឃ ព្រមទាំងមានពពក*មកបាំងព្រះអង្គបាត់ពីភ្នែកគេទៅ" (គម្ពីរកិច្ចការ ១:៩)។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត និង ការលើកទ្រង់ឡើង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅក្នុងការអធិប្បាយរបស់ពួកសាវ័ក (គម្ពីរកិច្ចការ ២:៣២-៣៥ គម្ពីរអេភេសូ ១:២០ គម្ពីរ១ពេត្រុស៣:២១-២២)។ ព្រឹត្តិការណ៍ទាំងពីរនេះ គឺជាចំណុចចាប់ផ្តើមនៃការលើកតម្កើងព្រះអម្ចាស់របស់យើងដែលត្រូវបានគេឆ្លាង ។

ពាក្យថា *ការលើកឡើងទៅ* គឺនិយាយអំពីព្រឹត្តិការណ៍ ដែលព្រះយេស៊ូបានត្រឡប់ទៅឯស្ថានបរមសុខវិញ។ ពាក្យថា *លើកតម្កើង* និយាយអំពីការ *"លើកឡើង"* "លើកឡើងដល់កម្រិតដ៏ខ្ពស់មួយ"។ ព្រះយេស៊ូត្រូវលើកឡើងដល់ឋានៈដ៏មានកិត្តិយស និង សិរីរុងរឿង នៅព្រះហស្តស្តាំរបស់ព្រះវរបិតា។នៅក្នុងការលើកឡើងទៅនគរស្ថានសួគ៌របស់ទ្រង់ ព្រះគ្រិស្តបានទទួលតំណែងស័ក្តិសមជាព្រះរាជាដែលគ្រងរាជ្យ (គម្ពីរកិច្ចការ ២:៣៣-៣៦; ៥:៣១ គម្ពីរអេភេសូ ១:១៩-២៣ គម្ពីរហេប្រឺ ២:១៤-១៨ ៤:១៤-១៦)។

ឋានៈដ៏ខ្ពង់ខ្ពស់នេះ មានក្លាយជាផលប្រយោជន៍ដ៏អស្ចារ្យសម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ដែលមានផលប្រយោជន៍ខ្លះយើងគួរតែកត់ចំណាំទុក៖

១. ឥឡូវនេះពេលដែលទ្រង់នៅឯនគរស្ថានសួគ៌ ព្រះយេស៊ូខាងឯវិញ្ញាណគង់នៅគ្រប់ទីកន្លែង នៅពេញសាកលលោកទាំងមូល (គម្ពីរអេភេសូ ៤:១០)។ ដូច្នេះទ្រង់សក្តិសមនឹងទទួលបានការថ្វាយបង្គំសម្រាប់មនុស្សគ្រប់ទាំងអស់ (គម្ពីរ១កូរិនថូស ១:២)។

២. ព្រះយេស៊ូបានយាងចូលទៅក្នុងព័ន្ធកិច្ចជាបូជាចារ្យរបស់ទ្រង់នៅស្ថានបរមសុខ ដូចដែលយើងបានបកស្រាយរួចមកហើយ (គម្ពីរហេប្រឺ ៤:១៤; ៥:៥-១០)។

៣. ទ្រង់បានប្រទានអំណោយទានមកឲ្យប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរអេភេសូ ៤:៨-១១)។ អំណោយទាននេះរាប់បញ្ចូលទាំងអំណោយទានសម្រាប់បុគ្គលម្នាក់ៗ (គម្ពីរ១កូរិនថូស ១២:៤-១១) និង អំណោយទានសម្រាប់ក្រុមជំនុំផងដែរ (គម្ពីរអេភេសូ ៤:៨ -១៣)។

៤. ទ្រង់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់មកលើប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរកិច្ចការ ២:៣៣)

៥. ក្នុងនាមជាព្រះរាជបុត្រា និង ជាព្រះសង្គ្រោះដែលគេលើកតម្កើង ទ្រង់បានប្រទានការកែប្រែចិត្ត និង ជំនឿទៅដល់មនុស្ស (គម្ពីរកិច្ចការ ៥:៣១; ១១:១៨ គម្ពីរ២ពេត្រុស ១:១)។

៦. ព្រះអម្ចាស់ដែលត្រូវបានលើកឡើងទៅនគរស្ថានសួគ៌ និង ត្រូវបានគេលើកតម្កើង ទ្រង់នឹងយាងទៅនគរស្ថានសួគ៌ក្នុងភាពជាមនុស្សរបស់ទ្រង់ (ព្រះកាយដ៏មានសិរីរុងរឿងរបស់ទ្រង់)។ គំនិតនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងលិខិតទៅកាន់សាសន៍ហេប្រឺ ដែលក្នុងនោះអ្នកនិពន្ធបានប្រកាសថា ដោយសារតែព្រះយេស៊ូបានឆ្លងកាត់បទពិសោធន៍ជាមនុស្ស ទ្រង់អាចក្លាយជាបូជាចារ្យដ៏ខ្ពស់ខ្ពស់ប្រកបដោយព្រះហឫទ័យមេត្តា និង ភាពស្មោះត្រង់ (គម្ពីរហេប្រឺ ២:១៤-១៨; ៤:១៤-១៦)។ នេះគឺជាប្រភពកម្លាំង និង ការកំសាន្តចិត្តដ៏អស្ចារ្យមួយ។

## *លំហាត់អនុវត្តន៍*

១៥ ចូរសរសេរនិយមន័យនៃពាក្យ *ការលើកឡើង* និង *ការលើកតម្កើង* ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

១៦ នៅក្នុងលំហាត់នេះ ចូរសរសេរលេខ ១ នៅខាងមុខប្រយោគដែលបង្ហាញពីលទ្ធផលនៃរាជកិច្ចរបស់ព្រះគ្រិស្តយ៉ាងត្រឹមត្រូវ ហើយសរសេរលេខ២ នៅខាងមុខប្រយោគណាដែលបង្ហាញមិនបានត្រឹមត្រូវ។

........ក) ព្រះគ្រិស្តបានបំពេញសាកលលោកនេះ ដូច្នេះហើយទ្រង់គឺជាព្រះដែលសមទទួលការថ្វាយបង្គំរបស់មនុស្សទាំងអស់។

........ខ) ព្រះគ្រិស្តបានបញ្ចប់កិច្ចការរបស់ទ្រង់សម្រាប់មនុស្សរួចហើយ ហើយទ្រង់លែងចូលទៅពាក់ព័ន្ធនឹងជីវិតខាងឯវិញ្ញាណរបស់ពួកគេទៀតហើយ។

.......គ) ព្រះគ្រិស្តបានយាងចូលទៅកាន់តំណែងជាបូជាចារ្យដ៏ខ្ពង់ខ្ពស់ សម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់។

.......ឃ) ព្រះគ្រិស្តប្រទានអំណោយទាន ទៅដល់បុគ្គលអ្នកជឿម្នាក់ៗ និងទៅដល់ក្រុមជំនុំទាំងមូល។

........ង) ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានចាក់បង្ហូរមកលើអ្នកជឿ។

........ច) ការសុគតរបស់ព្រះគ្រិស្ត បានបង់ថ្លៃលោះទោសបាប និង រំសាយព្រះពិរោធរបស់ព្រះជាម្ចាស់។

........ឆ) ការសុគតរបស់ព្រះគ្រិស្ត បានស្ដារទំនាក់ទំនងយ៉ាងពេញលេញរវាងព្រះជាម្ចាស់ និង មនុស្សជាតិ។

........ជ) អ្នកជឿមិនចាំបាច់ត្រូវអភិវឌ្ឍជីវិតខាងឯវិញ្ញាណរបស់ពួកគេតទៅទៀតនោះទេ ដោយសារតែព្រះយេស៊ូបានធ្វើការទាំងនោះអស់ហើយ។

.......ឈ) ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺជាការធានាសម្រាប់អ្នកជឿ ថា អស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្ត នឹងត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ។

---

យើងអាចឃើញថារាជកិច្ចទាំងអស់របស់ព្រះគ្រិស្តសុទ្ធតែមានអត្ថន័យយ៉ាងអស្ចារ្យសម្រាប់យើង។ តាមរយៈការសុគតរបស់ទ្រង់ ទ្រង់បានបង់ថ្លៃសម្រាប់ទោសបាបរបស់យើង។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ផ្ដល់ឲ្យយើងនូវការធានាថាមានជីវិតអស់កល្បជានិច្ចជាមួយទ្រង់។ តាមរយៈការលើកឡើងទៅឯស្ថានបរមសុខ និង ការលើកតម្កើងទ្រង់ ទ្រង់ត្រូវបានលើកឡើងឲ្យសមនឹងឋានៈរបស់ទ្រង់ជាព្រះអធិបតីនៃព្រះអម្ចាស់របស់យើងរាល់គ្នា។ ពេលនេះទ្រង់កសាង និង ថែរក្សាក្រុមជំនុំ ហើយប្រទានអ្វីៗដែលចាំបាច់ដើម្បីនាំឲ្យយើងបានពេញវ័យខាងឯវិញ្ញាណ។

# ការប្រឡងផ្ទាល់ខ្លួន

១ តើចម្លើយណាមួយនៅខាងក្រោមនេះ ជាភស្តុតាងអំពីភាពជាមនុស្សរបស់ព្រះគ្រិស្ត ដូចដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ?

ក) ដែនកំណត់របស់មនុស្ស និង ព្រះនាមជាមនុស្សរបស់ទ្រង់

ខ) មានបុព្វបុរសជាមនុស្ស

គ) មានពេញដោយបាបដូចមនុស្ស

ឃ) សណ្ឋាន និង ការលូតលាស់ជាមនុស្ស

២ ភស្តុតាងនៅក្នុងព្រះគម្ពីរ សម្រាប់ភាពជាព្រះរបស់ព្រះយេស៊ូគ្រិស្តបង្ហាញថា

ក) ទ្រង់បានប្រើប្រាស់សិទ្ធិជាព្រះរបស់ទ្រង់ទាំងអស់ជាប្រចាំ។

ខ) អាកប្បកិរិយារបស់ទ្រង់ ការអះអាងរបស់ទ្រង់ និង គុណសម្បត្តិរបស់ទ្រង់បង្ហាញថា ទ្រង់លើសពីមនុស្សធម្មតា។

គ) ភស្តុតាងគឺស្ថិតនៅត្រឹមការអះអាងផ្ទាល់របស់ទ្រង់ និង ទីបន្ទាល់នៃមិត្តភក្តិរបស់ទ្រង់។

៣ តើប្រយោគណាមួយនៅខាងក្រោមនេះ ឆ្លុះបញ្ចាំងយ៉ាងសុក្រិតជាងគេអំពីគោលលទ្ធិគ្រិស្តបរិស័ទទាក់ទងនឹងលក្ខណៈនៃការចាប់បដិសន្ធិរបស់ព្រះយេស៊ូ? ព្រះអម្ចាស់យេស៊ូគ្រិស្ត

ក) គឺជាព្រះជាម្ចាស់ដែលក្លែងធ្វើជាមនុស្ស។

ខ) មាននិស្ស័យជាមនុស្ស។

គ) មាននិស្ស័យជាព្រះជាម្ចាស់។

ឃ) ពិតជាព្រះជាម្ចាស់ ហើយពិតជាមនុស្ស។

៤ បទគម្ពីរបង្ហាញមកកាន់យើងថាព្រះយេស៊ូគ្រិស្ត

ក) គឺជាមនុស្សម្នាក់ដែលចាប់យកភាពជាព្រះ។

ខ) គឺជាអង្គព្រះជាម្ចាស់ដែលចាប់យកភាពជាមនុស្ស។

គ) មានគុណសម្បត្តិខ្លះ ដែលជាគុណសម្បត្តិរបស់មនុស្ស។

ឃ) មានគុណសម្បត្តិខ្លះ ដែលជាគុណសម្បត្តិរបស់ព្រះជាម្ចាស់។

៥ គោលបំណងដ៏ធំបំផុតនៃការចាប់បដិសន្ធិគឺ

ក) ដើម្បីជំរុញឲ្យផែនការនៃការប្រោសលោះមនុស្សជាតិរបស់ព្រះជាម្ចាស់មានដំណើរការ។

ខ) ដើម្បីបញ្ចប់អំណាចគ្រប់គ្រងនៃច្បាប់ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់។

គ) ដើម្បីសម្រេចឲ្យបាននូវគំរូសីលធម៌មួយសម្រាប់ឲ្យមនុស្សជាតិដើរតាម។

ឃ) ដើម្បីឲ្យមនុស្សបានស្គាល់ពីព្រះជាម្ចាស់។

៦ ការសុគតរបស់ព្រះគ្រិស្តត្រូវបានចាត់ទុកថាជារាជកិច្ចមួយ ព្រោះការសុគតនោះ

ក) គឺជាកិច្ចការដែលទ្រង់សព្វព្រះទ័យទទួលយក ដើម្បីបង់លោះទោសបាបរបស់យើង។

ខ) គឺមានជាប់ទាក់ទងនឹងការលះបង់ខាងឯរូបកាយ ក៏ដូចជាការធ្វើទុក្ខបុកម្នេញ និង ការស្លាប់ផងដែរ។

គ) គឺជាការបង្ខំលើទ្រង់។

៧ ការចាប់បដិសន្ធិគឺចាំបាច់ណាស់ ព្រោះ

ក) ព្រះគ្រិស្តត្រូវចាប់យករូបកាយជាមនុស្សដែលអាចស្លាប់ ដើម្បីទ្រង់អាចបង់លះទោសបាបរបស់យើងរាល់គ្នា។

ខ) ការនេះបានបង្ហាញ ពីព្រះវរបិតានៃស្ថានបរមសុខទៅចំពោះមនុស្ស។

គ) នៅក្នុងការចាប់បដិសន្ធិនេះ ព្រះជាម្ចាស់បានជ្រាបពីជម្រៅបាប និង ជ្រាបថាជាមនុស្សមានបាបមានន័យយ៉ាងណា។

ឃ) នៅក្នុងការចាប់ដិសន្ធិនេះ ព្រះគ្រិស្តបានប្រទានឲ្យយើងនូវគំរូមួយយ៉ាងល្អ។

៨ សារៈសំខាន់ដ៏ជាក់ស្តែងមួយ នៃការសុគតរបស់ព្រះគ្រិស្ត គឺមានជាប់ទាក់ទងជាមួយនឹងការឆ្លងភាពជាខ្លួនឯង។ នេះមានន័យថា អស់អ្នកដែលនៅជាប់ជាមួយនឹងព្រះគ្រិស្តត្រូវ

ក) ឆ្លងកាត់ការស្លាប់ដោយសារបាបរបស់ខ្លួនឯងដោយផ្ទាល់។

ខ) សម្លាប់និស្ស័យបាបរបស់ពួកគេ ព្រោះការសង្គ្រោះអនុញ្ញាតឲ្យពួកគេអាចរស់នៅក្នុងជីវិតដ៏វិសុទ្ធមួយបាន។

គ) ដឹងថា តាមរយៈការសុគតរបស់ព្រះគ្រិស្ត ទ្រង់បានដកចេញនិស្ស័យបាបរបស់ពួកគេ ដើម្បីឲ្យពួកគេបានទៅជាវិសុទ្ធពេញលេញ។

៩ រាជកិច្ចនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺមានសារៈសំខាន់ណាស់ ព្រោះ

ក) រាជកិច្ចនេះបង្ហាញពីការទទួលយករបស់ព្រះវរបិតា នូវការបូជារបស់ព្រះគ្រិស្ត ថាជាការទូលអង្វរជំនួសបាបរបស់មនុស្ស។

ខ) រាជកិច្ចនេះបញ្ជាក់ពីភាពជាព្រះរបស់ព្រះអម្ចាស់នៃយើង។

គ) រាជកិច្ចនេះធានាថា គ្រិស្តបរិស័ទមិនអាចធ្លាក់ចេញពីការគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។

ឃ) ព្រះគ្រិស្តគឺជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់របស់យើងដែល ចាំទូលអង្វរជំនួសយើងនៅក្នុងព្រះវត្តមានរបស់ព្រះវរបិតា។

ង) រាជកិច្ចនេះជាការធានាសម្រាប់គ្រិស្តបរិស័ទ ថាពួកគេនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញនៅពេលព្រះគ្រិស្តយាងត្រឡប់មកវិញ។

១០ ការលើកឡើងទៅស្ថានបរមសុខ និង ការលើកតម្កើង ព្រះអម្ចាស់នៃយើង គឺជាការសំខាន់ ព្រោះព្រឹត្តិការណ៍ទាំងអស់នេះ បាននាំមកនូវ

ក) ផ្នែកថ្មីនៃព័ន្ធកិច្ចរបស់ព្រះគ្រិស្តៈ ក្នុងនាមជាព្រះអធិបតី ទ្រង់ថែទាំ និង កសាងក្រុមជំនុំ ហើយព្រះវត្តមានរបស់ទ្រង់គឺមាននៅគ្រប់ទីកន្លែងទាំងអស់។

ខ) ទីបញ្ចប់នៃរាជកិច្ចរបស់ព្រះគ្រិស្តសម្រាប់មនុស្សជាតិ។

គ) ការចាប់ផ្តើមនៃការថ្វាយបង្គំដោយវិញ្ញាណដ៏ពិត។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ លើកលែងតែចម្លើយ ឃ)។

១ អ្នកត្រូវជ្រើសរើសចម្លើយ សតិបញ្ញា រូបកាយ វិញ្ញាណ និង សង្គម។ ព្រោះព្រះយេស៊ូ បានអភិវឌ្ឍទៅលើផ្លូវទាំងអស់នេះ។

១០ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

២ ក) និង ខ) ជាចម្លើយត្រឹមត្រូវ។

១១ ក) គ) និង ឃ) គឺជាមូលហេតុដ៏ស័ក្តិសម។

៣ ក) ៤)ដែនកំណត់ជាមនុស្ស

ខ) ៥)ព្រះនាមជាមនុស្ស

គ) ១)បុព្វបុរសជាមនុស្ស

ឃ) ៣)សណ្ឋានជាមនុស្ស

ង) ២)ការអភិវឌ្ឍន៍ជាមនុស្ស

១២ ចម្លើយផ្ទាល់ខ្លួនរបស់អ្នក។ យើងត្រូវធ្វើរឿងនេះជាប្រចាំថ្ងៃ។

៤ ទ្រង់ទទួលយកការថ្វាយបង្គំរបស់មនុស្ស ទ្រង់អត់ទោសបាប ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយទ្រង់ទទួលបានសិទ្ធិក្នុងការវិនិច្ឆ័យទោស របស់គ្រប់ទាំងអស់។

១៣ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

៥ ទ្រង់បង្ហាញពីភាពវិសុទ្ធរបស់ទ្រង់ ដោយការមិនប្រព្រឹត្តិបាបសោះ។ ទ្រង់បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ដោយ ការដាក់ខ្លួន ការបម្រើ និង ភាពទន់ភ្លន់របស់ទ្រង់ និងដោយទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ព្រះវរបិតា និង តាមរបៀបច្រើនផ្សេងទៀត។

១៤ ចម្លើយទាំងអស់សុទ្ធតែជាចម្លើយត្រឹមត្រូវ លើកលែងចម្លើយ ក) និង ង)

៦ ទ្រង់បានជ្រើសរើស ដាក់អង្គទ្រង់នៅក្នុងដែនកំណត់របស់មនុស្ស ដើម្បីឲ្យទ្រង់អាចបំពេញបេសកកម្មរបស់ទ្រង់ ក្នុងការសុគតជួសមនុស្សជាតិដែលពេញដោយបាប។

១៥ *ការលើកឡើង* សំដៅទៅលើព្រឹត្តិការណ៍ដែលព្រះគ្រិស្តយាងត្រឡប់ទៅនគរឋានសួគ៌វិញ ក្នុងព្រះកាយប្រកបដោយសិរីរុងរឿងរបស់ទ្រង់។ *ការលើកតម្កើង* សំដៅទៅលើការដែលព្រះយេស៊ូត្រូវបានគេលើកតម្កើង សមនឹងឋានៈដ៏មានកិត្តិយស និង សិរីរុងរឿង នៅឯព្រះហស្តស្តាំរបស់ព្រះវរបិតា។

៧ *គុណលក្ខណៈខាងឯសីលធម៌របស់ព្រះយេស៊ូ៖* ភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ទ្រង់។ *គុណលក្ខណៈពីធម្មជាតិរបស់ព្រះយេស៊ូ៖* ព្រះប្រាជ្ញាញាណ សព្វានុភាព សព្វញ្ញូតញាណ សព្វដ្ឋភាព និង ភាពអស់កល្បជានិច្ចរបស់ទ្រង់។ ការប្រៀបធៀប បង្ហាញឲ្យឃើញថាទាំងនេះសុទ្ធតែជាគុណលក្ខណៈរបស់ព្រះជាម្ចាស់។

១៦ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ លើកលែងតែចម្លើយ ខ) និង ជ)

៨ ក) ព្រះបន្ទូល (គម្ពីរយ៉ូហាន ១:១៤)

ខ) បុត្រារបស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១០:៣៦)

គ) ព្រះមេស្ស៊ី ព្រះគ្រិស្ត អ្នកដែលគេចាក់ប្រេងអភិសេក (គម្ពីរកិច្ចការ ២:៣៦)

ឃ) អេម៉ាញូអែល (គម្ពីរអេសាយ ៧:១៤)

ង) ព្រះអម្ចាស់ (គម្ពីរលូកា ២:១១)